**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ធ្លាក់ខារម៉ាកនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ហេង គឹមលី**

សាស្ត្រាចារ្យណែនាំ
លោក **ភាន់ សុទ្ធប៉ូលីន**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហេង គឹមលី** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី១៧ ក្រុម $L_4B_2$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទសូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញុតាធមិយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ៖

លោកឪពុក **ឡុន លាងហេង** និងអ្នកម្តាយ **ឡុង សុផល** គឺជាអ្នកមានគុណដ៏ធំធេងចំពោះរូបកូនដែលមិនអាចកាត់ថ្លៃបានឡើយ។ លោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនប្រកបដោយព្រហ្មវិហាធមិ ក្នុងការទំនុកបម្រុង គ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ថវិកា ស្មារតី សេចក្តីស្រលាញ់ និងបានផ្តល់នូវជំបូន្មានល្អៗ ជាពិសេសលោកបានផ្តល់ឱកាសដល់រូបកូនបានបន្តការសិក្សាថ្នាក់ឧត្តមសិក្សាដោយពុំឲ្យព្រួយបារម្ភអ្វីនោះឡើយ ។

កុង យាយ លោកឪពុកមា អ្នកម្តាយមីង បងប្អូន រៀមច្បងរួមសាកល មិត្តភក្តិទាំងអស់ ជាពិសេសបងស្រីបង្កើតរបស់ខ្ញុំ **លាងហេង ស៊ាងលីម** និងបងប្រុស **ហេង វុត្ថា** ដែលអ្នកទាំងអស់គ្នាតែងតែផ្តល់កម្លាំងចិត្តដ៏កក់ក្តៅ ក៏ដូចជាផ្តល់នូវយោបល់ និងគំនិតល្អៗជាច្រើនដល់រូបខ្ញុំបាទ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកនិងលោកស្រីសាស្ត្រាចារ្យ រួមទាំងបុគ្គលិកការិយាល័យស្រាវជ្រាវ និងបណ្ណារក្ស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការដឹកនាំគ្រប់គ្រងជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនរូបខ្ញុំបាទ ។

លោកសាស្ត្រាចារ្យ **កាន់ សុទ្ធប៉ូលីន** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្រៀនរូបខ្ញុំ ជាពិសេសទទួលយករូបខ្ញុំ និងបានជួយដឹកនាំ ផ្តល់យោបល់ល្អៗ ក៏ដូចជាកែសម្រួលយ៉ាងសកម្មដើម្បីធ្វើឲ្យសារណាមួយនេះអាចលេចចេញជារូបរាងឡើង។

លោក **អោប វ៉ាឌី** ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា លោកអនុប្រធាននាយកដ្ឋាន លោកនិងលោកស្រីប្រធានការិយាល័យទាំងប្រាំបួន ជាពិសេសបង **ឡៅ រាស៊ី** ដែលបានជួយផ្តល់ជាយោបល់ឯកសារសំខាន់ៗមួយចំនួន ជាពិសេសលោកបានអនុញ្ញាតឲ្យខ្ញុំបាទមានឱកាសបានចូលរៀនវគ្គ "ភ្នាក់ងារម៉ាកជំនាន់ទី៤" និងឯកឧត្តម **វ៉ា រ៉ុតសាន** ដែរតែងតែឆ្លើយតបរាល់សំនួររបស់ខ្ញុំបាទគ្រប់ពេលទោះបីជាឯកឧត្តម មមាញឹកនឹងកិច្ចការរាជការយ៉ាងណាក៏ដោយ។

ជាទីបញ្ចប់នេះ ខ្ញុំបាទ សូមគោរពជូនពរដល់អ្នកមានគុណទាំងអស់ សូមជួបតែសំណាងល្អ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងលំអិតរយៈពេល៤ឆ្នាំកន្លងមកលើផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ដើម្បីជាសក្ខីភាព និងជាស្នាដៃជំនួយដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី "**ភ្នាក់ងារម៉ាកនៅកម្ពុជា**" យកមកធ្វើជាប្រធានបទក្នុងការសិក្សាសារជ្រាវ ដើម្បីចងក្រងជារបាយការណ៍បញ្ចប់ការសិក្សា ដោយមានការណែនាំពីសំណាក់លោកសាស្ត្រាចារ្យ **កាន់ សុទ្ធប៉ូលីន** ដែលប្រកបដោយជំនាញ និងបទពិសោធន៍យ៉ាងស្ទាត់លើមុខវិជ្ជានីតិកម្មសិទ្ធិបញ្ញា។

ដោយយោងលើភាពជាក់ស្តែងចំពោះ ការអនុវត្តច្បាប់ទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញានៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសបទបញ្ញត្តិទាក់ទងទៅនឹងភ្នាក់ងារម៉ាក គឺនៅមានកម្រិតនៅឡើយ រីឯលិខិតបទដ្ឋានផ្សេងៗទៀត យើងឃើញថា នៅមានចំនុចមួយចំនួនស្ថិតក្នុងភាពមិនច្បាស់លាស់ និងខ្វះខាតយ៉ាងខ្លាំង។ ដូចនេះ ចំពោះខ្លឹមសាររបស់របាយការណ៍នេះ គឺជាមូលដ្ឋាននៃចំណេះដឹងដ៏ប្រសើរមួយដែលអាចបញ្ជាក់ ឲ្យឃើញពីប្រវត្តិដំបូងនៃវត្តមានភ្នាក់ងារម៉ាកនៅកម្ពុជា និងលក្ខខណ្ឌគុណវុឌ្ឍិព្រមទាំងសមត្ថកិច្ចរបស់ភ្នាក់ងារម៉ាកនៅកម្ពុជាកាន់តែច្បាស់ថែមទៀត។

ទន្ទឹមនឹងនេះដែរ ខ្ញុំបាទសង្ឃឹមថារបាយការណ៍មួយនេះ នឹងជួយបង្ហាញឲ្យឃើញពីសារៈសំខាន់នៃតួនាទីភ្នាក់ងារម៉ាកក្នុងកិច្ចដំណើរការចុះបញ្ជីម៉ាកនៅកម្ពុជា ក៏ដូចជាការជួយពង្រឹងច្បាប់ទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញាផងដែរ ដើម្បីការពារម្ចាស់ម៉ាក និងធានាបាននូវការធ្វើអាជីវកម្មប្រកបដោយសុវត្ថិភាព និងការប្រកួតប្រជែងដោយស្មោះត្រង់។

ទោះជាយ៉ាងនេះក្តី ដោយសារចំណេះដឹងមូលដ្ឋានខ្ញុំបាទនៅមានកម្រិត ហើយរបាយការណ៍នេះជាស្នាដៃដំបូង រួមផ្សំនឹងពេលវេលាខ្លីទៀតនោះ ខ្ញុំបាទជឿជាក់ថា ពិតជាមានចំណុចខ្វះខាតជាក់ជាពុំខានឡើយ។ ហេតុដូច្នេះ ខ្ញុំបាទសូមអភ័យទោសទុកជាមុន រាល់កំហុសដែលកើតមានឡើងដោយអចេតនាទាំងនោះ និងរីករាយស្វាគមន៍ ចំពោះយោបល់រិះគន់ និងការទិទៀនដើម្បីកែលម្អក្នុងន័យស្ថាបនាស្នាដៃមួយនេះគ្រប់ពេលវេលា៕

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី ១

## ប្រវត្តិនៃភ្នាក់ងារម៉ាកនៅកម្ពុជា

**១.១. ការកកើតភ្នាក់ងារម៉ាកដំបូងនៅកម្ពុជា** ............................................................ ៥

១.១.១ ភ្នាក់ងារម៉ាកនៅមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ............................................................ ៥

១.១.១.១. ភ្នាក់ងារម៉ាកមុនរបបកម្ពុជាប្រជាធិបតេយ្យ ............................................................ ៦

១.១.១.២. ភ្នាក់ងារម៉ាកក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ............................................................ ៨

១.១.២. ភ្នាក់ងារម៉ាកនៅក្រោយឆ្នាំ១៩៩៣ ............................................................ ៩

១.១.២.១. ភ្នាក់ងារម៉ាកមុនឆ្នាំ២០១៣ ............................................................ ៩

១.១.២.២. ភ្នាក់ងារម៉ាកក្រោយឆ្នាំ២០១៣ ............................................................ ១១

**១.២. មូលដ្ឋានគតិយុត្តបច្ចុប្បន្ន និង សារប្រយោជន៍នៃភ្នាក់ងារម៉ាក** ............................................................ ១២

១.២.១. លិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងភ្នាក់ងារម៉ាក ............................................................ ១២

១.២.២. សារប្រយោជន៍នៃភ្នាក់ងារម៉ាកនៅក្នុងវិស័យម៉ាក ............................................................ ១៤

## ជំពូកទី ២

## ក្របខណ្ឌគុណវុឌ្ឍិ និង សមត្ថកិច្ចរបស់ភ្នាក់ងារម៉ាក

**២.១.លក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក** ............................................................ ១៩

២.១.១ យន្តការដើម្បីទទួលបានគុណវុឌ្ឍិជាភ្នាក់ងារម៉ាក ............................................................ ១៩

២.១.១.១. ការទទួលបានតាមរយៈការប្រកួតប្រជែង ............................................................ ១៩

២.១.១.២. ទទួលបានដោយស្វ័យប្រវត្តិ ............................................................ ២២

២.១.២ មូលហេតុនៃការបាត់បង់គុណវុឌ្ឍិជាភ្នាក់ងារម៉ាក ............................................................ ២៣

២.១.២.១. ដោយឆន្ទៈផ្ទាល់ខ្លួន..........................................................................២៤

២.១.២.២. ដោយកំហុសធ្ងន់ធ្ងរ...........................................................................២៤

២.១.២.៣. ដោយហេតុផ្សេងៗ ...........................................................................២៤

**២.២.សមត្ថកិច្ចភ្នាក់ងារម៉ាក** ...........................................................................២៥

២.២.១ ភ្នាក់ងារម៉ាកជាភ្នាក់ងារតំណាងម៉ាករបស់ម្ចាស់ម៉ាក ....................................២៥

២.២.១.១. ភ្នាក់ងារម៉ាកនៅក្នុងនីតិវិធីចុះបញ្ជីម៉ាក ..............................................២៥

២.២.១.២. ភ្នាក់ងារម៉ាកនៅក្នុងនីតិវិធីដោះស្រាយវិវាទម៉ាក.................................. ២៧

២.២.២ ភ្នាក់ងារម៉ាកជាជំនួយការរបស់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្មម៉ាក ...............២៨

២.២.២.១. ភ្នាក់ងារម៉ាកនៅក្នុងប្រតិបត្តិការនៃកិច្ចសន្យា .......................................២៨

២.២.២.២. ភ្នាក់ងារម៉ាកនៅក្នុងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា ......................... ៣០

**សេចក្តីសន្និដ្ឋាន**............................................................................................ ៣២

**អនុសាសន៍**.................................................................................................... ៣៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ភ្នាក់ងារម៉ាកគឺ ជាបុគ្គលដែលតំណាងដោយស្របច្បាប់ឲ្យម្ចាស់ម៉ាកក្នុងការស្នើសុំចុះបញ្ជីម៉ាក និងជាពិសេសការពារផលប្រយោជន៍ម្ចាស់ម៉ាកជាចម្បង។ ឬអាចនិយាយបានម្យ៉ាងទៀតថា ភ្នាក់ងារម៉ាកគឺ ជាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការតំណាងឲ្យម្ចាស់ម៉ាក។

ភ្នាក់ងារម៉ាក បើនិយាយក្នុងបរិបទប្រទេសអភិវឌ្ឍន៍ ត្រូវបានប្រជាជនជាទូទៅស្គាល់យ៉ាងច្បាស់អំពីតួនាទី និងភារកិច្ចរបស់បុគ្គលតំណាងនេះ ព្រោះថា ភ្នាក់ងារម៉ាក បានកកើត និងទទួលស្គាល់នៅតាមបណ្តាលប្រទេសទាំងនោះយូរណាស់មកហើយ។ ជាក់ស្តែងនៅ សហរដ្ឋអាមេរិក៖ គេបានដាក់បញ្ចូលយន្តការតំណាងម៉ាក នៅក្នុងច្បាប់ម៉ាកដោយហៅជាភាសាជាតិខ្លួនថាTrademark attorney[១] (មេធាវីម៉ាក)។ រីឯប្រទេសជប៉ុន ក៏បានដាក់បញ្ចូលយន្តការតំណាងម៉ាកនៅក្នុងច្បាប់ម៉ាករបស់ខ្លួន ដោយហៅថា Trademark agent[២] (ភ្នាក់ងារកម្មសិទ្ធិបញ្ញា)។ មិនខុសគ្នាប៉ុន្មានដែរ ប្រទេសបារាំង យន្តការតំណាងក្នុងវិស័យកម្មសិទ្ធិបញ្ញាត្រូវបាន ហៅជាភាសាជាតិថា Conseil de la propriété industrielle[៣] (ក្រុមប្រឹក្សាកម្មសិទ្ធិឧស្សាហកម្ម) និងប្រទេសចិន បានដាក់បញ្ចូលយន្តការតំណាងម៉ាកនៅក្នុងច្បាប់ម៉ាករបស់ខ្លួន ដោយហៅថា Trademark agent[៤] (ភ្នាក់ងារម៉ាក)។

ដោយឡែកក្នុងបរិបទប្រទេសកម្ពុជាវិញ ភ្នាក់ងារម៉ាកជាសញ្ញាណមួយដែលមិនថ្មីពេក ហើយក៏មិនចាស់ពេកនោះដែរ។ មិនថ្មីពេកដោយសារវត្តមានភ្នាក់ងារម៉ាក បានកកើតតាំងពីសម័យសង្គមរាស្ត្រនិយមមកម្លេះ។ ក៏ប៉ុន្តែដោយសាររបបនយោបាយរបស់កម្ពុជាផ្លាស់ប្តូរ ទើបធ្វើឲ្យយន្តការតំណាងដោយភ្នាក់ងារម៉ាកនេះ បានបាត់បង់លែងដំណើរការ គួបផ្សំនឹងការសម្លាប់ប្រជាជនដ៏ច្រើនផងនោះ។ ទើបមកដល់ពេលនេះមានប្រជាជនតិចណាស់ដែរស្គាល់ពីភ្នាក់ងារម៉ាក។ រីឯការដែរពោលថាមិនចាស់ពេកវិញ ក៏ព្រោះថាតាំងឆ្នាំ១៩៩១មក វត្តមានភ្នាក់ងារម៉ាកបានចាប់បដិសន្ធិសារជាថ្មី ហើយបានបន្តវត្តមានរបស់ខ្លួនរហូតសល់បច្ចុប្បន្ន។ តែទោះជាយ៉ាងនេះក៏ដោយ មានប្រជាជនតិចណាស់ដែរស្គាល់ និងយល់ច្បាស់អំពីតួនាទីរបស់ភ្នាក់ងារម៉ាក។ ខុសស្រឡះពីភ្នាក់ងារម៉ាក ប្រជាជនជាទូទៅបានស្គាល់ និងយល់អំពីម៉ាកច្រើន បើទោះបីជាប្រជាជននៅជនបទក៏ដោយ។ ព្រោះថាក្នុងពេលបច្ចុប្បន្ន នេះប្រជាជនភាគច្រើនមានទំនោរជាខ្លាំងទៅលើការប្រើប្រាស់ផលិតផលដែលមានម៉ាក

[១] U.S. Trademark Law, U.S. Patent & Trademark Office, December 28,2009 សម្រាប់ទទួលបានទិន្នន័យសូមចូលទៅកាន់៖ https://www.uspto.gov/sites/default/files/trademarks/law/Trademark_Statutes.pdf

[២]តំណរភ្ជាប់សម្រាប់ព័ត៌លំអិតទាក់ទងនឹងទិន្នន័យនៃការចុះបញ្ជីម៉ាកនៅកម្ពុជា៖ www.wipo.int/wipolex/en/text.jsp?file_id=188401

[៣] តំណរភ្ជាប់សម្រាប់ព័ត៌លំអិតទាក់ទងនឹងទិន្នន័យនៃការចុះបញ្ជីម៉ាកនៅកម្ពុជា ៖ www.cncpi.fr/sta144-44-LA-CNCPI.htm

[៤]តំណរភ្ជាប់សម្រាប់ព័ត៌លំអិតទាក់ទងនឹងទិន្នន័យនៃការចុះបញ្ជីម៉ាកនៅកម្ពុជា៖ www.wipo.int/wipolex/en/details.jsp?id=13198

សញ្ញាសម្គាល់។ នេះអាចនិយាយបានថា ការយល់ដឹងរបស់ប្រជាពលរដ្ឋជាទូទៅអំពីភ្នាក់ងារម៉ាក ហាក់នៅមានកម្រិតនៅឡើយ។

ការបង្កើតភ្នាក់ងារម៉ាក នៅក្នុងវិស័យម៉ាកមិនមែនជាការចៃដន្យនោះទេ។ ភ្នាក់ងារម៉ាកត្រូវបានបង្កើតឡើង គឺដើម្បីជាឧបករណ៍គតិយុត្តសម្រាប់ជាជំនួយ និងគ្រប់គ្រងការងារស្នើសុំចុះបញ្ជីម៉ាករួមទាំងកិច្ចការផ្សេងៗពាក់ព័ន្ធនឹងម៉ាក។ ក្នុងនោះយើងសង្កេតឃើញមានការវិវត្តនៃលិខិតបទដ្ឋានជាបន្តបន្ទាប់ សម្រាប់គ្រប់គ្រងភ្នាក់ងារម៉ាក។ សូមរំលឹកមកក្រោយបន្តិចថា ឆ្នាំ១៩៩១ភ្នាក់ងារម៉ាកបានកើតឡើងតាមរយៈលិខិតលេខ៤៥២ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការអនុញ្ញាតឲ្យប្រមូលកម្រៃលើការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក គឺកើតឡើងក្នុងពេលដែលពុំទាន់មានភ្នាក់ងារម៉ាក និងស្របតាមស្ថានភាពនៃតម្រូវការចំពោះមុខក្នុងយន្តការតំណាងឲ្យម្ចាស់ម៉ាកបរទេសដែលបានស្នើសុំចុះបញ្ជីម៉ាក។ ដោយសារហេតុផលខាងលើនេះហើយ ទើបភ្នាក់ងារម៉ាកបានកើតឡើងតាមរយៈការស្នើសុំទទួលស្គាល់ ឬអាចហៅម៉្យាងទៀតថា ភ្នាក់ងារម៉ាកដែលផ្អែកលើការទទួលស្គាល់ ព្រោះកាលនោះយើងពុំទាន់មានច្បាប់គោលសម្រាប់គ្រប់គ្រងលើភ្នាក់ងារម៉ាកនៅឡើយ គឺការអនុវត្តកើតមុនច្បាប់។ បន្ទាប់មកនៅឆ្នាំ២០០២ ទើបយើងឃើញមានច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវបានប្រកាសឲ្យប្រើ។ នេះគឺជាច្បាប់គោលសម្រាប់គ្រប់គ្រងវិស័យម៉ាក តែហាក់មិនបានចែងលំអិតអំពីភ្នាក់ងារម៉ាកនោះទេ។ សូម្បីតែចំណុចនិយាយអំពីលក្ខខណ្ឌដើម្បីក្លាយជាភ្នាក់ងារម៉ាក និងសមត្ថកិច្ចក៏ពុំមានចែងលំអិតដែរ។ ដោយមូលហេតុនេះហើយ បានជានៅឆ្នាំ២០១១ក្រសួងពាណិជ្ជកម្មបានចេញសេចក្តីប្រកាសស្តីពី ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈប្រកាសនេះហើយ ដែលបានបង្ហាញឲ្យយើងបានយល់អំពីលក្ខណៈសម្បត្តិគតិយុត្តរបស់ភ្នាក់ងារម៉ាក ឬហៅបានម៉្យាងទៀតថា ភ្នាក់ងារម៉ាកដែលផ្អែកលើគុណវុឌ្ឍិ។ គួសបញ្ជាក់ដែរថា ការលើកយកលិខិតបទដ្ឋានពាក់ព័ន្ធនឹងភ្នាក់ងារម៉ាកមកបង្ហាញគឺ ដើម្បីឲ្យប្រជាពលរដ្ឋទូទៅបានយល់អំពីដំណើរប្រព្រឹត្តទៅនៃតួនាទីរបស់ភ្នាក់ងារម៉ាក លើវិថីកម្មសិទ្ធិបញ្ញាដ៏ក្មេងខ្ចីរបស់កម្ពុជាថាតើមានមូលដ្ឋានគតិយុត្តអ្វីខ្លះសំរាប់ការពារដល់ដំណើរប្រព្រឹត្តទៅរបស់ភ្នាក់ងារម៉ាក? និងតើអ្វីទៅជាសារប្រយោជន៍ ដែលកើតចេញពីកិច្ចគតិយុត្តរបស់ភ្នាក់ងារម៉ាក?

ដើម្បីដោះស្រាយបញ្ហាចោទខាងលើ ទើបស្នាដៃមួយនេះត្រូវបានប្រសូត្រឡើងក្នុងគោលបំណងបម្រើអ្នកអានទាំងឡាយនូវខ្លឹមសារសំខាន់ៗ ដោយរំលេចនូវការពន្យល់ពីប្រវត្តិនៃភ្នាក់ងារម៉ាកនៅកម្ពុជា ដើម្បីបង្ហាញពីមូលដ្ឋាននៃការកកើតដំបូងរបស់ភ្នាក់ងារម៉ាកព្រមជាមួយនឹងការវិវត្ត។ ម៉្យាងទៀត ក៏មានបំណងឲ្យបុគ្គលទាំងអស់បានសិក្សាស្វែងយល់ និងធ្វើការពិចារណាទៅលើមូលដ្ឋានគតិយុត្តជាតិនៃភ្នាក់ងារម៉ាក ឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីបានជាប្រយោជន៍នៅក្នុងជីវភាពរបស់ខ្លួន។ បន្ថែមលើសពីនេះ ក៏មានបំណងធ្វើការរំលេចនូវ សមត្ថកិច្ចក៏ដូចជាសារប្រយោជន៍នៃភ្នាក់ងារម៉ាកក្នុងប្រព័ន្ធកម្មសិទ្ធិបញ្ញា។

សារប្រយោជន៍ជាសារវ័ន្តមកវិញ ក្នុងការសិក្សាអំពីភ្នាក់ងារម៉ាកនៅកម្ពុជា សម្រាប់ជាការពិចារណា និងស្វែងយល់កាន់តែច្បាស់ពីទិដ្ឋភាពច្បាប់សំរាប់គ្រប់គ្រងភ្នាក់ងារម៉ាក ភាពចាំបាច់នៃវត្តមានរបស់ភ្នាក់ងារម៉ាកក្នុងវិស័យកម្មសិទ្ធិបញ្ញា ក៏ដូចជាការចូលរួមសកម្មភាពអភិវឌ្ឍន៍ជាតិរបស់ភ្នាក់ងារម៉ាក និងដើម្បីបានជាជំនួយនៃប្រភពឯកសារជាតិដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញាជាអាទិ៍។

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាចោទខាងលើ ការបកស្រាយនឹងធ្វើឡើងតែក្នុងវង្វង់នៃបរិបទប្រទេសកម្ពុជាតែប៉ុណ្ណោះ ដោយដកចេញនូវបរិបទតំបន់ និងអន្តរជាតិដែលពាក់ព័ន្ធនឹងភ្នាក់ងារម៉ាក។ ដូចនេះដើម្បីងាយស្រួលក្នុងការបង្ហាញពីខ្លឹមសារជាសារវ័ន្តនៃប្រធានបទ ពាក់ព័ន្ធនឹងភ្នាក់ងារម៉ាកនៅកម្ពុជា ខ្ញុំនឹងធ្វើការបែងចែកប្រធានបទនេះជា ២ជំពូកធំៗដូចខាងក្រោម៖

**ជំពូកទី១៖ ប្រវត្តិនៃភ្នាក់ងារម៉ាកនៅកម្ពុជា** ក្នុងជំពូកនេះយើងនឹងសិក្សាលើពីរចំណុចសំខាន់ៗបន្តទៀតគឺចំណុច១.១ការកកើតភ្នាក់ងារម៉ាកដំបូងនៅកម្ពុជា និងចំណុច១.២មូលដ្ឋានគតិយុត្តបច្ចុប្បន្ន និងសារប្រយោជន៍នៃភ្នាក់ងារម៉ាក។

**ជំពូកទី២៖ ក្របខណ្ឌគុណវុឌ្ឍិ និងសមត្ថកិច្ចរបស់ភ្នាក់ងារម៉ាក** ដូចគ្នាដែរក្នុងជំពូកនេះយើងនឹងសិក្សាលើពីរចំណុចសំខាន់ៗគឺចំណុច២.១លក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក និងចំណុច២.២ សមត្ថកិច្ចភ្នាក់ងារម៉ាក។

# ជំពូកទី ១

# ប្រវត្តិនៃភ្នាក់ងារម៉ាកនៅកម្ពុជា

សញ្ញាណនៃភ្នាក់ងារម៉ាក មានវត្តមាននៅលើទឹកដីនៃប្រទេសកម្ពុជាតាំងពីទសវត្សទី៦០មក ហើយយើងអាចកត់សម្គាល់បានតាមរយៈភស្តុតាង ដែលក្រសួងពាណិជ្ជកម្មបានប្រមូលចងក្រងទុកជាឯកសារបានបង្ហាញឲ្យឃើញថា គឺវត្តមាននៃម៉ាកបរទេសចំនួនពីរត្រូវបានអនុញ្ញាតឲ្យចុះបញ្ជីការពារនៅលើទឹកដីកម្ពុជា។ ការនេះបានបង្ហាញឲ្យឃើញ ពីការប្រើប្រាស់យន្តការតំណាងភ្នាក់ងារម៉ាកក្នុងដំណើរការចុះបញ្ជីម៉ាកបរទេស ព្រោះថាម៉ាកបរទេសពុំអាចចុះបញ្ជីម៉ាកដោយខ្លួនឯងផ្ទាល់បានឡើយ គឺចាំបាច់ត្រូវតែធ្វើឡើយដោយភ្នាក់ងារម៉ាក។

ក្រោយបញ្ចប់សង្គ្រាមស៊ីវិល កម្ពុជាបានចាប់ផ្តើមកសាងមូលដ្ឋានគ្រឹះកម្មសិទ្ធិបញ្ញាឡើងវិញតាមរយៈជំនួយបច្ចេកទេសពីអ្នកជំនាញកម្មសិទ្ធិបញ្ញា ជាពិសេសអង្គការកម្មសិទ្ធិបញ្ញាពិភពលោកតែម្តង។ ក្នុងពេលជាមួយគ្នា កម្ពុជាក៏បានអនុញ្ញាតឲ្យមានប្រព័ន្ធចុះបញ្ជីម៉ាក ទាំងម៉ាកក្នុងប្រទេស និងម៉ាកបរទេស។ ជាលទ្ធផលនៅឆ្នាំ១៩៩១ កម្ពុជាទទួលបានពាក្យស្នើសុំចុះបញ្ជីម៉ាកសរុបចំនួន៧៩ និងសម្រេចអនុញ្ញាតចុះបញ្ជីម៉ាកចំនួន៨ម៉ាក[៥]។ ជាការកត់សម្គាល់ម៉ាកបរទេសទាំង៧៩ បានដាក់ពាក្យស្នើសុំចុះបញ្ជីបានតាមរយៈភ្នាក់ងារម៉ាក[៦]។ ក្រោយមកច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវបានប្រកាសឲ្យប្រើថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២។ ប៉ុន្តែ ខ្លឹមសារច្បាប់ពុំបានចែងលម្អិតអំពីភ្នាក់ងារម៉ាកឲ្យបានច្បាស់លាស់នោះទេ គឺ គ្រាន់តែបញ្ជាក់ត្រឹមតែការចុះបញ្ជីម៉ាកបរទេសត្រូវតែធ្វើឡើងតាមរយៈភ្នាក់ងារម៉ាក។ ក្រោមមកទើបក្រសួងពាណិជ្ជកម្ម ចេញប្រកាសមួយលេខ០៤៥ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបង្ហាញពីសារៈសំខាន់នៃភ្នាក់ងារម៉ាកក្នុងការផ្តល់ភាពងាយស្រួលដល់ម្ចាស់ម៉ាកដើម្បីធ្វើអាជីវកម្ម និងការពារសិទ្ធិរបស់ខ្លួនតាមរយៈ តំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

តាមរយៈការស្រាវជ្រាវនៅក្នុងជំពូកនេះយើងនឹងបង្ហាញអំពី ការកកើតនៃភ្នាក់ងារម៉ាកដំបូងនៅកម្ពុជា (១.១) ដើម្បីស្វែងយល់ពីប្រវត្តិខ្លះៗនៃភ្នាក់ងារប្រភេទនេះ មុននឹងយើងធ្វើការស្វែងយល់ជាបន្តអំពី មូលដ្ឋានគតយុត្តិបច្ចុប្បន្ន និងសារសំខាន់នៃភ្នាក់ងារម៉ាកនៅក្នុងប្រព័ន្ធច្បាប់កម្មសិទ្ធិបញ្ញានៅកម្ពុជា(១.២)។

[៥] តំណរភ្ជាប់សម្រាប់ព័ត៌មានលំអិតទាក់ទងនឹងទិន្នន័យនៃការចុះបញ្ជីម៉ាកនៅកម្ពុជា៖ http://www.wipo.int/branddb/kh/en/។

[៦] ភ្នាក់ងារម៉ាកដែលប្រតិបត្តិកិច្ចការតំណាងឲ្យម្ចាស់ម៉ាកបរទេសក្នុងដំណើរការចុះបញ្ជី គឺកើតចេញពីលិខិតអនុញ្ញាតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីដែរអនុញ្ញាឲ្យប្រមូលកម្រៃសេវាចុះបញ្ជី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩១។

## ១.១. ការកកើតភ្នាក់ងារម៉ាកដំបូងនៅកម្ពុជា

តាមរយៈភស្តុតាងដែលបានចងក្រងដោយក្រសួងពាណិជ្ជកម្ម បានបង្ហាញពីវត្តមានភ្នាក់ងារម៉ាកក្នុងវិស័យកម្មសិទ្ធិបញ្ញាតាំងពីទសវត្សទី៦០មក។ ក្រោយមកវិស័យម៉ាក ក៏ដូចជាភ្នាក់ងារម៉ាកត្រូវបាត់បង់ពីប្រព័ន្ធច្បាប់កម្ពុជា ដោយសារបញ្ហាសង្គ្រាមផ្ទៃក្នុងអូសបន្លាយអស់ជាច្រើនទសវត្ស។ លុះមកដល់ឆ្នាំ១៩៩១ វិស័យម៉ាកបានចាប់កំណើតឡើងវិញព្រមគ្នានឹងភ្នាក់ងារម៉ាក ដោយស្ថិតក្រោមកិច្ចសហប្រតិបត្តិការ និងជំនួយបច្ចេកទេសពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

បន្ទាប់ពីពេលនោះមក ភ្នាក់ងារម៉ាកបានកកើតឡើងជាបន្តបន្ទាប់សម្រាប់បំពេញតាមតម្រូវការចំពោះមុខ ពីព្រោះថាមានម៉ាកបរទេសជាច្រើនបានដាក់ពាក្យស្នើសុំចុះបញ្ជី។ ជាការកត់សំគាល់ក្នុងពេលនោះ ការអនុវត្តកិច្ចការងារចុះបញ្ជីម៉ាកធ្វើឡើងមុនមានច្បាប់ ក៏ដូចគ្នាដែរភ្នាក់ងារម៉ាកដែរអនុវត្តកិច្ចការរបស់ខ្លួនក៏ពុំមានច្បាប់ចែងកំណត់ឲ្យបានច្បាស់លាស់អ្វីនោះដែរ ដោយគ្រាន់តែអនុវត្តដោយយោងលើលិខិតអនុញ្ញាតឲ្យប្រមូលកម្រៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រីតែប៉ុណ្ណោះ[៧]។ រហូតដល់ឆ្នាំ២០០២ ទើបយើងមានច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ សម្រាប់គ្រប់គ្រងវិស័យម៉ាក និងចង្អុលបង្ហាញអំពីកិច្ចការរបស់ភ្នាក់ងារម៉ាក តែវានៅមិនគ្រប់គ្រាន់ឡើយ។ ទើបតែនៅឆ្នាំ២០១៣ មានប្រកាសមួយបានកំណត់អំពីភ្នាក់ងារម៉ាក ដើម្បីបំពេញបន្ថែមនៃច្បាប់ម៉ាកកាលពីឆ្នាំ២០០២។

ដូចបានបង្ហាញរួចខ្លះមកហើយអំពីដំណើរដើមទងនៃការកកើតភ្នាក់ងារម៉ាកនៅកម្ពុជា។ បន្ទាប់ពីនេះ យើងនឹងសិក្សាលំអិតតាមដំណាក់កាលវិវត្តនីមួយៗនៃភ្នាក់ងារម៉ាក ដោយចាប់ផ្តើមពីការវិវត្តមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ (១.១.១) និងភ្នាក់ងារម៉ាកនៅក្រោយឆ្នាំ១៩៩៣ (១.១.២) ។

### ១.១.១ ភ្នាក់ងារម៉ាកនៅមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

ដូចបានរៀបរាប់ពីខាងលើរួចមកហើយ វត្តមាននៃភ្នាក់ងារម៉ាកនៅក្នុងប្រទេសកម្ពុជា ត្រូវបានរកឃើញតាមរយៈ លទ្ធផលការងារក្នុងការប្រមូលចងក្រងរក្សាទុក នូវឯកសាររបស់ក្រសួងពាណិជ្ជកម្ម។ ហើយដោយសារបញ្ហាប្រឈមដែលកើតមកលើប្រទេសកាលសម័យនោះ បានធ្វើឲ្យបាត់បង់រាល់បណ្តុំឯកសារគតិយុត្តនានាដែរពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញានិយាយជារួម និងនិយាយដោយឡែកគឺវិស័យម៉ាកនេះតែម្តង។ ក្រោយមកដោយសារ របបនយោបាយជាតិមាននិន្នាការទៅរករបបទីផ្សារសេរី បានជំរុញឲ្យកម្ពុជាងាកមកអភិវឌ្ឍន៍កសាងបទដ្ឋានសម្រាប់គ្រប់គ្រងវិស័យពាណិជ្ជកម្ម រួមទាំងវិស័យម៉ាក និងភ្នាក់ងារម៉ាកផងដែរ។

[៧] យោងឯកសារបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាលភ្នាក់ងារម៉ាកជំនាន់ទី៣, ការអភិវឌ្ឍកម្មសិទ្ធិបញ្ញានៅកម្ពុជា, Penn Sovicheat, ទំព័រទី៣៦, ឆ្នាំ២០១៦។ សូមមើលនៅក្នុងឧបួសម្ព័ន្ធ៣។

ក្នុងការសិក្សាក៏បានបង្ហាញផងដែរពី ភាពប្តូរផ្លាស់ និងការវិវត្តជាហូរហែនៃភ្នាក់ងារម៉ាកនៅកម្ពុជា ដែលជាហេតុ នាំឲ្យយើងធ្វើការបែងចែកជាពីរដំណាក់កាលវិវត្តធំៗ៖ ក្នុងដំណាក់កាលទីមួយ យើងនឹងសិក្សាអំពី ភ្នាក់ងារម៉ាកមុនការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ(១.១.១.១.) និងដំណាក់កាលទីពីរយើងនឹងសិក្សាបន្ថែមលើ ភ្នាក់ងារម៉ាកក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ(១.១.១.២) ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ឲ្យបានកាន់តែលំអិត ពាក់ព័ន្ធនឹងដំណើរប្រព្រឹត្តទៅរបស់ភ្នាក់ងារម៉ាកក្នុងដំណាក់កាលទាំងពីរខាងក្រោម។

### ១.១.១.១. ភ្នាក់ងារម៉ាកមុនរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងសម័យសង្គមរាស្ត្រនិយម ប្រទេសកម្ពុជា បានរីកចំរើនលើគ្រប់វិស័យ រួមទាំងវិស័យពាណិជ្ជកម្មផងដែរ ក្នុងនោះទស្សនទាននៃកិច្ចការពារម៉ាកបានស្តែងឡើងតាមរយៈការអនុញ្ញាតឲ្យចុះបញ្ជីការពារលើម៉ាកបរទេសចំនួនពីរ[៨] រួមមាន៖**ម៉ាកPERTUSSIN** ស្ថិតនៅក្នុងជំពូកទី៥ ដែលមានលេខដាក់ពាក្យ១៩៧៣ ក្នុងឆ្នាំ១៩៦៦ ជាប្រភេទពាណិជ្ជសញ្ញា សម្រាប់ប្រើលើផលិតផលប្រភេទឱសថ និងបរិក្ខាថ្នាំពេទ្យ និង**ម៉ាកRIBENA** ស្ថិតនៅក្នុងជំពូកទី៥ និង៣២ ដែលមានលេខដាក់ពាក្យ១០៣១៨ នៅក្នុងឆ្នាំ១៩៧៣[៩]។ ភស្តុតាងដែរបានបង្ហាញនេះ បាននាំយើងឲ្យដឹងថា ម៉ាកទាំងពីរប្រភេទនេះ គឺជាប្រភេទពាណិជ្ជសញ្ញា សម្រាប់ប្រើលើផលិតផលប្រភេទ ឱសថ និងទឹកសុទ្ធឬទឹកផ្លែឈើជាអាទ៏។ ហើយតាមរយៈលទ្ធផលនេះអាចឲ្យយើងយល់បានថា ការអនុវត្តច្បាប់ម៉ាកនៅក្នុងប្រទេស អាចបណ្តាលមកពីឥទ្ធិពលរបស់បារាំង តាមរយៈការធ្វើអាណានិគមមកលើប្រទេសកម្ពុជា ដោយបានផ្លាស់ប្តូរទាំងប្រព័ន្ធគ្រប់គ្រងប្រទេស៖ រដ្ឋបាល ពាណិជ្ជកម្ម អប់រំ សេដ្ឋកិច្ចជាអាទ៏។តែអ្វីដែលធ្វើឲ្យយើងសោកស្តាយនោះគឺ រាល់ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ជាពិសេសម៉ាក ត្រូវបានបំផ្លិចបំផ្លាញអស់គ្មានសល់ ជាហេតុធ្វើឲ្យមានការលំបាកក្នុងការសិក្សាស្រាវជ្រាវក៏ដូចជាការបង្ហាញភស្តុតាងឲ្យជាក់ច្បាស់។ ម្យ៉ាងវិញទៀតយើងអាចយល់បានថាម៉ាកទាំងពីរខាងលើបានបាត់បង់នូវភាពពេញលេញនៃឯកសារដើមរួចទៅហើយ។ ពីព្រោះយើងពុំឃើញមានចំនុចដែលបញ្ជាក់អំពីអ្នកស្នើសុំចុះបញ្ជីនោះទេ។ ដើម្បីជាប្រយោជន៍ជាយើងត្រូវដឹងថា៖ តើពាក្យស្នើសុំចុះបញ្ជីធ្វើឡើងដោយនរណា? តើអាចជាម្ចាស់ម៉ាកផ្ទាល់ ឬដោយភ្នាក់ងារតំណាងម៉ាក?

[៨] ការបង្ហាញពីទិន្នន័យចុះបញ្ជីម៉ាកខាងលើនេះពុំមែនមានន័យថា ក្នុងសម័យសង្គមរាស្ត្រនិយមប្រទេសកម្ពុជា មានម៉ាកដែរត្រូវការពារតែពីរនេះនោះទេ ពីព្រោះទិន្នន័យពីរដែរបានបង្ហាញនេះ គឺជាភស្តុតាងដែរបានសេសសល់ក្រោយពីការបំផ្លិចបំផ្លាញពីសំណាក់របបកម្ពុជាប្រជាធិបតេយ្យ និងពីការចង់ចាំរបស់មន្ត្រីយើងដែររួចរស់ជីវិតពីសម័យដ៏ខ្មៅងងឹតនោះ។ នេះបានសេចក្តីថា នៅមានម៉ាកជាច្រើនទៀតដែរ កម្ពុជាបានអនុញ្ញាតចុះបញ្ជីការពារឲ្យ ដោយគ្រាន់តែយើងបានបាត់បង់ទិន្នន័យទាំងនោះ ជាហេតុធ្វើឲ្យយើងមិនអាចបញ្ជាក់ពីព័ត៌មានទាំងនោះច្បាស់។

[៩] នាយកដ្ឋានកម្មសិទ្ធិបញ្ញា, ប្រវត្តិនៃនាយកដ្ឋាន, www.cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=39&childMasterMenuId= 29,(ដកស្រង់កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧)។

ដើម្បីអាចឆ្លើយទៅនឹងសំនួរខាងលើ ខ្ញុំសូមទាញបង្ហាញនូវគោលការណ៍ច្បាប់ជាសកលស្តីពីអំពីគោលការណ៍ដែនដីនៃរដ្ឋ។ យោងតាមធម្មនុញ្ញអង្គការសហប្រជាជាតិ មាត្រា២ កថាខណ្ឌ១ ″អង្គការសហប្រជាជាតិឈរលើគោលការណ៍នៃសមភាព អធិបតេយ្យរបស់សមាជិកទាំងអស់របស់ខ្លួន។″ តាមរយៈអត្ថន័យខាងលើយើងអាចយល់បានថា គោលការណ៍សមភាព សំដៅទៅលើភាពស្មើមុខស្មើមាត់គ្នាក្នុងឋានៈជារដ្ឋមួយ ទោះបីជារដ្ឋតូចក្តី ធំក្តី រដ្ឋអភិវឌ្ឍន៍ក្តី រដ្ឋកំពុងអភិវឌ្ឍន៍ក្តី។ ដោយឡែកគោលការណ៍អធិបតេយ្យ សំដៅលើភាពដែលមិនអាចរំលោភបំពានបានតាមគ្រប់រូបភាពនូវបូរណភាពទឹកដីនៃរដ្ឋនីមួយៗ។ តាមរយៈគោលការណ៍ពីរខាងលើនេះយើងឃើញថា នៅក្នុងគោលការណ៍ដែនដីនៃរដ្ឋ មានធាតុផ្សំរបស់គោលការណ៍ពីរចំណុះឲ្យ។ ដូចនេះយើងអាចយល់បានថា គោលការណ៍ដែនដីនៃរដ្ឋ ជាគោលការណ៍ដ៏ពិសិដ្ឋមួយនៅក្នុងទំនាក់ទង់អន្តរជាតិ ដែលតម្រូវគ្រប់រដ្ឋទាំងអស់នៃបណ្តាសមាជិករបស់អង្គការសហប្រជាជាតិត្រូវតែគោរពតាម។ បន្ថែមលើសពីនេះនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ត្រង់មាត្រ៥៥បានចែងថា ″សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល។″ ក្នុងន័យនេះហើយនៅពេលដែរម្ចាស់ម៉ាកបរទេសនៃរដ្ឋមួយចូលមកចុះបញ្ជីម៉ាកនៅក្នុងដែនដីនៃប្រទេសកម្ពុជា ចាំបាច់ត្រូវតែគោរពតាមអធិបតេយ្យភាពរបស់កម្ពុជា។ ស្របតាមមាត្រាខាងលើសបញ្ជាក់ឲ្យឃើញថា ម៉ាកបរទេសពីរខាងលើដែលបានទទួលការអនុញ្ញាតឲ្យចុះបញ្ជីនៅកម្ពុជានោះមិនអាចចុះបញ្ជីដោយខ្លួនឯងឡើយ ពិតណាស់ថាមានតែធ្វើឡើងតាមរយៈក្របខណ្ឌច្បាប់របស់កម្ពុជាប៉ុណ្ណោះទើបអាចអនុវត្តន៍បាន។

ជាសក្ខីភាពម៉ាកបរទេស អាចចុះបញ្ជីការពារម៉ាករបស់ខ្លួននៅក្នុងទឹកដីនៃរដ្ឋដ៏ទៃចាំបាច់ត្រូវគោរពតាមគោលការណ៍តំណាងសិទ្ធិនៃរដ្ឋនោះ បើមិនដូចនោះទេ ម្ចាស់ម៉ាកបរទេសនោះពុំអាចចុះបញ្ជីការពារម៉ាករបស់ខ្លួនបានឡើយ នេះគឺជាគោលការណ៍ទូទៅ ឬអាចនិយាយបានថាជាគោលការណ៍ដែលរណបទៅនឹងគោលការណ៍ដែនដីរបស់រដ្ឋ។

ដូចយើងបានដឹងហើយថានៅឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបានផ្លាស់ប្តូររបបដឹកនាំប្រទេសឈានឆ្ពោះទៅរកលទ្ធិកុម្មុនីសម៉ៅសេទុង។ កាលនោះប្រទេសជាតិទាំងមូលបានបំផ្លិចបំផ្លាញស្ទើរវិនាសប្រទេស ដោយប្រជាជនត្រូវបានកាប់សម្លាប់អស់ប្រមាណជាង៣លាននាក់ រីឯវិស័យសម្រាប់គ្រប់គ្រងប្រទេសវិញក៏ត្រូវបានផ្លាស់ប្តូរ និងលុបចោលអស់គ្មានសល់ ហើយបើនិយាយពីឯកសារទាក់ទងនឹងវិស័យម៉ាកវិញក៏មានវាសនាមិនខុសពីប្រជាពលរដ្ឋដែរ ពីព្រោះវិស័យម៉ាកមិនត្រូវបានយកមកដាក់បញ្ចូលក្នុងគោលនយោបាយជាតិសម្រាប់អភិវឌ្ឍន៍ប្រទេសនោះទេ។ ដោយហេតុថាវិស័យកម្មសិទ្ធិបញ្ញា គឺជាផ្នែកមួយនៃវិស័យពាណិជ្ជកម្ម ហើយវិស័យពាណិជ្ជកម្ម គឺជាកត្តាដែលនាំឲ្យមានការបែងចែកវណ្ណៈនៅក្នុងសង្គម ដែលវាផ្ទុយទៅនឹងគោលនយោបាយជាតិរបស់ខ្មែរក្រហម គឺ″រស់នៅ

ដោយភាពស្មើគ្នា គ្មានឡើយវណ្ណៈគហបតីមូលធន អ្វីៗអង្គការជាអ្នកបែងចែក[១០]"។ ទាំងនេះហើយ ដែលជាមូលហេតុដែលនាំអវត្តមាននៃវិស័យម៉ាក ក៏ដូចជាភ្នាក់ងារម៉ាកនៅកម្ពុជា។

### ១.១.១.២. ភ្នាក់ងារម៉ាកក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំទៅហើយក្តី ក៏វិស័យពាណិជ្ជកម្មជាពិសេស វិស័យម៉ាក នៅតែពុំមានវត្តមានក្នុងសកម្មភាពអភិវឌ្ឍន៍ប្រទេសឡើយ។ មូលហេតុដែលនាំឲ្យអវត្តមាននៃវិស័យម៉ាកក្រោយពេលរបបខ្មែរក្រហមដួលរលំទៅ មានកត្តាពីរចម្បងៗៈ

កត្តាគោលនយោបាយរបស់រដ្ឋ[១១] ដែលស្តែងឡើងតាមរយៈរដ្ឋធម្មនុញ្ញត្រង់មាត្រា១១"សេដ្ឋកិច្ចជាតិស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋ។ រដ្ឋលើកស្ទួយជីវភាពរបស់ប្រជាជន ឲ្យមានកំរិតខ្ពស់ជាលំដាប់លើគ្រប់ផ្នែកដើម្បីកសាងប្រទេសជាតិ។" តាមរយៈអត្ថន័យមាត្រានេះ បានបង្ហាញឲ្យឃើញពីស្ថានភាពជារួមនៃប្រទេសក្នុងវិស័យសេដ្ឋកិច្ច គឺគ្មានសកម្មភាពរបស់វិស័យឯកជនក្នុងប្រតិបត្តិការសកម្មភាពពាណិជ្ជកម្មរបស់ខ្លួននោះទេ គឺមានតែតួអង្គរដ្ឋមួយគត់ ដែលជាអ្នកដឹកនាំ និងគ្រប់គ្រងលើកិច្ចការនេះ។ ហេតុនេះ ហើយបានជាវិស័យម៉ាកជាពិសេសភ្នាក់ងារម៉ាកគ្មានវត្តមានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចជាតិកើត។ និង

កត្តាកង្វះខាតធនធានមនុស្ស កើតឡើងដោយសាររបបខ្មែរក្រហមបានសម្លាប់ចោលបណ្ឌិតសាស្ត្រាចារ្យ បញ្ញាវន្ត និងអ្នកចេះដឹងទាំងឡាយ ស្ទើរផុតពូជ។ រីឯអ្នកដែលនៅសល់ បន្តសំងំលាក់ខ្លួនបន្តទៀត ដោយសារការភ័យខ្លាច ការមិនប្រាកដប្រជាលើរបបដឹកនាំថ្មី... ជាហេតុនាំឲ្យ យើងគ្មានលទ្ធភាពក្នុងការបង្កើតនូវលិខិតបទដ្ឋានគតិយុត្តិនានា សម្រាប់គាំទ្រដល់វិស័យកម្មសិទ្ធិបញ្ញា ក៏ដូចជាបណ្តុះបណ្តាលឲ្យមានភ្នាក់ងារតំណាងម៉ាក សម្រាប់អនុវត្តយន្តការតំណាងឲ្យម្ចាស់ម៉ាកក្នុងការចុះបញ្ជីម៉ាកជាអាទិ៍។ ជារួមយើងអាចទាញសន្និដ្ឋានតាមរយៈកត្តាទាំងពីរបានថា ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្មានឡើយច្បាប់ឬបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងលើកិច្ចការពាណិជ្ជកម្មម៉ាក និងភ្នាក់ងារម៉ាកតែម្តង ព្រោះថាប្រទេសកម្ពុជាក្នុងពេលនោះប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចបែបផែនការ គឺរដ្ឋជាអ្នកផ្គត់ផ្គង់សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រីឯប្រជាជនវិញអនុវត្តកិច្ចការតាមការដឹកនាំរបស់រដ្ឋតែប៉ុណ្ណោះ។

អវត្តមានរបស់ភ្នាក់ងារម៉ាកបានបន្តហូតដល់ ដល់ចុងឆ្នាំ១៩៨០ ទើបមានសញ្ញាណលេចឡើងពីការគិតគូរបង្កើតមូលដ្ឋានគ្រឹះនៃវិស័យកម្មសិទ្ធិបញ្ញា តាមរយៈការធ្វើកំណែទម្រង់ប្រទេស ទៅរក

[១០] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, ជំពូក៤,មាត្រា៤ ចែងថាៈ កម្ពុជាប្រជាធិបតេយ្យ អនុវត្តរបបសមូហភាព ក្នុងការដឹកនាំ និងធ្វើការងារ។

[១១] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, មាត្រា១១។

សេដ្ឋកិច្ចបែបទីផ្សារសេរី គួបផ្សំនឹងបម្រែបម្រួលនយោបាយក្នុងប្រទេសផង។ មូលហេតុនៃការកើតឡើងវិញគឺដោយមានការរួមផ្សំរវាងពីរស្ថានការណ៍ៈ ដោយស្ថានការណ៍ទីមួយគឺ បន្ទាប់ពីរបត់នយោបាយកម្ពុជាបានផ្លាស់ប្តូរទៅរករបបសេដ្ឋកិច្ចទីផ្សារសេរី និងមានការរីកចម្រើនកាន់តែប្រសើរ បន្ទាប់ពីកម្ពុជាចូលជាសមាជិកនៃ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក[១២] សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន[១៣] និងអង្គការពាណិជ្ជកម្មពិភពលោក[១៤] ក៏ដូចជាការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាមួយចំនួនផ្សេងទៀត។ ស្ថានការណ៍ទីពីរគឺ ដោយមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីបញ្ចប់ជម្លោះរវាងខ្មែរនិងខ្មែរ ទើបកម្ពុជាមានឱកាសគ្រប់គ្រាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ។ ដោយស្តែងតាមរយៈលទ្ធផលនៃកំណែទម្រង់របបនយោបាយជាតិ តើនឹងមានឥទ្ធិពលយ៉ាងណាលើវិស័យកម្មសិទ្ធិបញ្ញាកម្ពុជា?

### ១.១.២. ភ្នាក់ងារម៉ាកនៅក្រោយឆ្នាំ១៩៩៣

ការផ្តើមកសាងឡើងវិញនូវមូលដ្ឋានគ្រឹះកម្មសិទ្ធិបញ្ញា បានស្តែងឡើងក្រោមកិច្ចខិតខំប្រឹងប្រែងសហការពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក តាមរយៈជំនួយបច្ចេកទេស សម្ភារៈ និងមន្ត្រីជំនាញខាងកម្មសិទ្ធិបញ្ញាក្នុងការរៀបចំបង្រៀនបច្ចេកទេសដល់មន្ត្រីអនុវត្ត និងរៀបចំតាក់តែងលិខិតបទដ្ឋានបច្ចេកទេសសម្រាប់កិច្ចប្រតិបត្តិការងារលើវិស័យនេះតែម្តង។ កាលទេសនៃការចាប់ផ្តើមកសាងវិស័យកម្មសិទ្ធិបញ្ញាដំបូង ស្ថិតនៅក្រោមស្ថានភាពខ្វះខាតច្បាប់ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តការងារចំពោះមុខយ៉ាងខ្លាំង។ តែទោះជាយ៉ាងណាក៏ដោយ ក្រោយការខិតខំប្រឹងប្រែងទើបលេចចេញជាផ្លែផ្ការហូតមកដល់ពេលបច្ចុប្បន្ន។ តាមរយៈផ្លែផ្កានេះ យើងនឹងទាញចំណាប់អារម្មណ៍ជាពិសេសចំពោះភ្នាក់ងារម៉ាកមុនឆ្នាំ២០១៣ (១.១.២.១) និងភ្នាក់ងារម៉ាកក្រោយឆ្នាំ២០១៣ (១.១.២.២)

#### ១.១.២.១. ភ្នាក់ងារម៉ាកមុនឆ្នាំ២០១៣

ដូចធ្លាប់បានបញ្ជាក់នៅខាងលើរួចមកហើយថា ដោយមានកិច្ចព្រមព្រៀងទីក្រុងប៉ារីនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ វិស័យកម្មសិទ្ធិបញ្ញាត្រូវចាប់ផ្តើមដំណើរការឡើងវិញ។ ជាលទ្ធផលនៅឆ្នាំ១៩៩១

[១២] កម្ពុជាចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ដើម្បីស្វែងយល់បន្ថែមសូមចូលទៅកាន់ http://www.wipo.int/members/en/details.jsp?country_id=90។

[១៣] កម្ពុជាចូលជាសមាជិករបស់អាស៊ាន នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩ ១៩៩៥ ដើម្បីស្វែងយល់បន្ថែមសូមចូលទៅកាន់ www.ukessays.com/essays/economics/asean-and-history-of-cambodias-membership-economics-essay.php

[១៤] កម្ពុជាចូលជាសមាជិកទី១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ ដើម្បីស្វែងយល់បន្ថែមសូមចូលទៅកាន់ https://www.wto.org/english/thewto_e/acc_e/a1_cambodge_e.htm ។

ក្រសួងពាណិជ្ជកម្ម បានបង្កើតការិយាល័យពាណិជ្ជសញ្ញា ដែលមានភារកិច្ចទទួលចុះបញ្ជីម៉ាក និងការពារពាណិជ្ជសញ្ញា ដោយទទួលបានការគាំទ្រ និងជួយជ្រោមជ្រែងបណ្ដុះបណ្ដាលផ្នែកបច្ចេកទេសពីប្រទេសនានា ជាពិសេស អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (world Intellectual Property Organization-WIPO) ដែលមានមូលដ្ឋាននៅក្នុងទីក្រុងហ្សឺណែវ នៃប្រទេសស្វីស។ ចំពោះការចុះបញ្ជីម៉ាក កាលនោះធ្វើឡើងតាមរយៈលិខិតអនុញ្ញាតពីទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩១ ដែលបានផ្ដល់សិទ្ធិជាភ្នាក់ងារតំណាង សម្រាប់អនុវត្តន៍កិច្ចការចុះបញ្ជីរបស់ម្ចាស់ម៉ាក (ម៉ាកបរទេស)។អ្វីដែលគួរឲ្យកត់សម្គាល់ក្នុងពេលនោះគឺ លិខិតពុំបានកំណត់ និងចែងឲ្យបានច្បាស់លាស់ពីលក្ខណៈសម្បត្តិគតិយុត្ត ឬនីតិវិធីទទួលបានភាពស្របច្បាប់ជាភ្នាក់ងារតំណាងអ្វីឡើយ។ ដោយសារបញ្ហានេះហើយទើបមេធាវី ឬការិយាល័យប្រឹក្សាច្បាប់ អាចធ្វើជាភ្នាក់ងារតំណាងឲ្យម្ចាស់ម៉ាកបានដោយយោងទៅលើចំណេះដឹងផ្នែកច្បាប់ និងជំនាញផ្ទាល់របស់ខ្លួន ដើម្បីសម្របតាមស្ថានភាពចាំបាច់ចំពោះមុខ។ ដោយក្នុងនោះមេធាវីបានអះអាងអំពីភាពជាតំណាងឲ្យម្ចាស់ម៉ាកដោយផ្អែកទៅលើមាត្រា៤ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ចែងថា៖ *"ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬគាត់តែងលិខិតស្នាមគតិយុត្តបានឡើយ[...]។"* យោងតាមមាត្រានេះ រាល់សកម្មភាពក្នុងការផ្ដល់សេវាកម្មច្បាប់ រួមបញ្ចូលទាំងការប្រឹក្សាយោបល់ផ្នែកច្បាប់ ការចុះហត្ថលេខាលើលិខិតស្នាមគតិយុត្តផ្សេងៗ ឬសេវាពាក់ព័ន្ធផ្នែកច្បាប់ក្នុងគោលដៅយកកម្រៃជាសិទ្ធិ និងសមត្ថកិច្ចរបស់មេធាវីតែមួយគត់។ ដោយឡែកក្នុងករណីចុះបញ្ជីម៉ាក ការបំពេញពាក្យស្នើសុំចុះបញ្ជីម៉ាក ឬការចុះហត្ថលេខាលើពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាពិគ្រោះយោបល់ផ្សេងៗទៀតពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាក ជាប្រភេទនៃសេវាកម្មច្បាប់ដែលអនុញ្ញាតឲ្យមេធាវីមានសិទ្ធិក្នុងការធ្វើកិច្ចទាំងឡាយដូចបានរៀបរាប់ខាងលើ ក្នុងគោលដៅយកប្រាក់កម្រៃស្របតាមមាត្រា៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

បន្ទាប់មកច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់បានប្រកាសឲ្យប្រើរួចមកបានធ្វើឲ្យមានការប្រែប្រួលយ៉ាងខ្លាំង ទៅលើពាក្យ "ភ្នាក់ងារតំណាងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" នៃមាត្រា៥៩។ ដោយភ្នាក់ងារម៉ាកដែលកើតមុនច្បាប់ទាំងនោះ ត្រូវផ្លាស់ប្តូរទម្រង់នៃការហៅទៅជាភ្នាក់ងារម៉ាកដែលខ្វះលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រោះថា ភ្នាក់ងារម៉ាកទាំងនោះពុំទាន់បានបំពេញលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់។ គួរកត់សម្គាល់ផលដែរថា ការផ្លាស់ប្តូរពាក្យពេចន៍នៃភ្នាក់ងារម៉ាក គឺពុំមានអានុភាពប៉ះពាល់ទៅដល់តួនាទីជាអ្នកតំណាងឲ្យម្ចាស់ម៉ាកទាំងនោះឡើយ។ ព្រោះថាស្ថានភាពកាលនោះនៅមិនទាន់មានប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីកំណត់អំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃភ្នាក់ងារម៉ាក ដូចនេះប្រសិនបើឈប់ទទួលស្គាល់ភ្នាក់ងារម៉ាកដែរកំពុងអនុវត្តកិច្ចនាពេលនោះទេ នឹងលេចឡើងនូវបញ្ហាចោទជាក់ជាមិនខាន។ អ្វីដែរជាបញ្ហាចោទចំបងបំផុតនោះគឺ តើមាននរណាជាអ្នកអនុវត្តន៍ យន្តការតំណាងម្ចាស់ម៉ាក? ដោយសារស្ថានភាពនេះហើយ ទើបភ្នាក់ងារម៉ាកទាំងនោះនៅតែអាចអនុវត្តតួនាទីតំណាងរបស់ខ្លួនដដែរ។

ក្រោយមកនៅឆ្នាំ២០០៥ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានចេញតារាងទទួលស្គាល់ភ្នាក់ងារម៉ាក ចំនួន៨[១៥]ដែលឈរតំណាងឲ្យនីតិបុគ្គល។ នេះគឺជាការទទួលស្គាល់ជាផ្លូវការថ្មីស្រឡាង បន្ទាប់ពីច្បាប់ម៉ាកប្រកាសឲ្យប្រើ។ តាមរយៈការទទួលស្គាល់នេះយើងមិនអាចសន្និដ្ឋានបានថា ភ្នាក់ងារទាំង៨នោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយឬនៅនោះទេ? ព្រោះថា ដើម្បីដឹងអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ យើងត្រូវរង់ចាំមើលប្រកាសដែលមានកំណត់នៅក្នុងមាត្រា៥៩នៃច្បាប់ម៉ាកជាមុនសិន។ ផ្ទុយទៅវិញ ប្រសិនបើយើងពិចារណាស្របតាមមាត្រា៥៩នៃច្បាប់ក្នុងន័យចង្អៀត ច្បាស់ណាស់ថាភ្នាក់ងារទាំង៨ខាងលើនោះក៏នៅពុំទាន់ក្លាយជាភ្នាក់ងារម៉ាកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅឡើយទេ។

### ១.១.២.២. ភ្នាក់ងារម៉ាកក្រោយឆ្នាំ២០១៣

អ្វីដែលជាចម្ងល់ ក៏ដូចជាកង្វល់ទាក់ទងនឹងលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ភ្នាក់ងារម៉ាក នឹងត្រូវបានស្រាយបំភ្លឺតាមរយៈប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា[១៦] ប្រកាសឲ្យប្រើកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។ តាមរយៈប្រការ៨នៃប្រកាសនេះ យើងអាចយល់បានថា ភ្នាក់ងារម៉ាកដែរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចាំបាច់ត្រូវមានលក្ខខណ្ឌ៥ចម្បងៗដូចជា៖

ភ្នាក់ងារម៉ាកត្រូវមានសញ្ជាតិខ្មែរ ត្រង់ចំនុចនេះ គ្រប់បុគ្គលដែរទទួលបានសញ្ជាតិខ្មែរស្របតាមច្បាប់កំណត់ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងប្រឡងដើម្បីក្លាយជាភ្នាក់ងារម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ត្រូវមាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាក្លាយខ្លួនជាភ្នាក់ងារម៉ាកក៏ដោយ ប្រសិនបើភ្នាក់ងារនោះពុំមានទីតាំងនៃជីវភាពរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ នោះភ្នាក់ងារតំណាងនឹងបាត់បង់លក្ខណៈសម្បត្តិគ្រប់គ្រាន់នៃភ្នាក់ងារស្របច្បាប់ជាមិនខាន។ ជាគោលគំនិតប្រសិនបើភ្នាក់ងារម៉ាកមិនមាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅកម្ពុជាទេ វានឹងធ្វើឲ្យមានភាពពិបាក និងយឺតយូរក្នុងដំណើរការចុះបញ្ជីម៉ាក ហើយអ្វីដែរសំខាន់ វានឹងធ្វើឲ្យផលប្រយោជន៍របស់ម្ចាស់ម៉ាកត្រូវប្រឈមនឹងការខូតខាត។

ត្រូវមានទីតាំងប្រកបអាជីវកម្ម ឬការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអាចប្រកបអាជីវកម្មបាន ចាំបាច់ភ្នាក់ងារម៉ាកត្រូវតែក្លាយជានីតិបុគ្គលជាមុនសិន ឬឈរឈ្មោះតំណាងឲ្យនីតិបុគ្គលណាមួយ ទើបអាចដាក់ពាក្យស្នើសុំការទទួលស្គាល់ភាពជាតំណាងភ្នាក់ងារម៉ាកស្របច្បាប់ពីក្រសួងពាណិជ្ជកម្មបាន។

---

[១៥] សូមមើលនៅឧបសម្ព័ន្ធ ៥។

[១៦] ប្រកាសស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា, លេខ០៤៥ Moc/SM2011, ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១(ពីពេលនេះតទៅហៅថាប្រកាសស្តីពីភ្នាក់ងារម៉ាក)។ សូមមើលនៅឧបសម្ព័ន្ធ ១។

ត្រូវប្រឡងជាប់ជាស្ថាពរក្នុងការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឬត្រូវបានចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ដូចមានចែងក្នុងប្រការ២៦ នេះជាលក្ខខណ្ឌដ៏សំខាន់របស់ភ្នាក់ងារម៉ាក ដែលចាំបាច់ត្រូវតែមានសមត្ថភាពខ្ពស់ក្នុងការទទួលបានជោគជ័យសម្រាប់ការប្រឡង និងមិនផ្ទុយនឹងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

ជាលទ្ធផលនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ភ្នាក់ងារម៉ាកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជំនាន់ទី១ ចំនួន៣៤ត្រូវបានប្រឡងជាប់ជាស្ថាពរ នឹងត្រូវបានទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម។ គិតមកដល់ពេលនេះមានភ្នាក់ងារម៉ាកបីជំនាន់បានបណ្តុះបណ្តាលនឹងប្រឡងរួចជាស្ថាពរ និងជំនាន់ទី៤បានបញ្ចប់វគ្គបណ្តុះបណ្តាល និងកំពុងត្រៀមប្រឡងបញ្ចប់ជំនាន់។ សូមបញ្ជាក់ផងដែរថា ចំនួនសរុបនៃភ្នាក់ងារម៉ាកដែរមានលក្ខខណ្ឌសម្បត្តិគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់ និងប្រកាសមានចំនួន៤២[១៧]ភ្នាក់ងារម៉ាកប៉ុណ្ណោះ គិតត្រឹមថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧។

## ១.២. មូលដ្ឋានគតិយុត្តបច្ចុប្បន្ន និង សារប្រយោជន៍នៃភ្នាក់ងារម៉ាក

ដោយសារស្ថានភាពរបស់ភ្នាក់ងារម៉ាកមានការវិវត្តច្រើន ទើបយើងចាំបាច់ត្រូវតែសិក្សាជុំវិញលិខិតបទដ្ឋានគតិយុត្តិនានាដែរពាក់ព័ន្ធនឹងភ្នាក់ងារម៉ាក។ ការសិក្សាអំពីរបបគតិយុត្តិបាននាំយើងឲ្យយល់ដឹងអំពីភ្នាក់ងារម៉ាកកាន់តែស៊ីជម្រៅបន្ថែមទៀត ព្រោះថាគ្រប់សកម្មភាពគតិយុត្តរបស់ភ្នាក់ងារម៉ាកអាចស្តែងឡើងបាន គឺអាស្រ័យតាមច្បាប់កំណត់ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនានាផងដែរ។ បើមិនដូចនោះទេ គ្រប់សកម្មភាពប្រតិបត្តិរបស់ភ្នាក់ងារម៉ាកនឹងត្រូវប្រឈមចំពោះមុខច្បាប់ជាក់ជាពុំខាន។ ដោយសារមូលហេតុនេះហើយ ទើបធ្វើឲ្យយើងអាចមើលឃើញពីសារប្រយោជន៍របស់ភ្នាក់ងារម៉ាក។ តើភ្នាក់ងារម៉ាកអនុវត្តកិច្ចរបស់ខ្លួនបានដោយសំអាងទៅលើអ្វីខ្លះ? និង អ្វីជាសារប្រយោជន៍ដែលកើតចេញពីការប្រើប្រាស់ភ្នាក់ងារម៉ាក?

អនុលោមតាមបញ្ហាពីរខាងលើ យើងនឹងធ្វើការបង្ហាញឲ្យកាន់តែលំអិតអំពីទិដ្ឋភាពនៃ លិខិតបទដ្ឋានគតិយុត្តិនៅចំនុច១.២.១ និងសារប្រយោជន៍នៃភ្នាក់ងារម៉ាកនៅចំនុច១.២.២។

### ១.២.១. លិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងភ្នាក់ងារម៉ាក

ដើម្បីធានាដល់ដំណើរការអនុវត្តតួនាទីរបស់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក កម្ពុជាបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្តិមួយចំនួនមានជាអាទ៍៖

[១៧] គួរបញ្ជាក់ផលដែរថា ភ្នាក់ងារម៉ាកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ ជារៀងរាល់មួយឆ្នាំម្តង ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម។ ដូចនេះតាមរយៈបញ្ជីឈ្មោះភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឆ្នាំ២០១៥– ២០១៦ ដែលចេញដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា មានត្រឹមតែ៤២ភ្នាក់ងារម៉ាកតែប៉ុណ្ណោះ។ តំណរភ្ជាប់ដើម្បីទាញយកទិន្នន័យលំអិត៖ www.cambodiaip.gov.kh/TemplateTwo.aspx?parentId=78&menuid=320&childMasterMenuId=320

- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ។ គោលគំនិតសំខាន់នៃច្បាប់ទាក់ទងនឹងភ្នាក់ងារម៉ាកបានស្តែងឡើង ដោយមានពីរមាត្រាគឺមាត្រា៥៨ និងមាត្រា៥៩។ តាមរយៈមាត្រាទាំងពីរ អាចឲ្យយើងស្វែងយល់បានលើពីរទិដ្ឋភាពជុំវិញភ្នាក់ងារម៉ាក។ **ទិដ្ឋភាពទីមួយ** ឆ្លុះបញ្ចាំងអំពីតួនាទីជាតំណាងស្របច្បាប់របស់ម្ចាស់ម៉ាកក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ក្នុងករណីដែរម្ចាស់ម៉ាកនោះពុំមាន ទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ក្នុងព្រះរាជាណាចក្រកម្ពុជា។ រីឯភ្នាក់ងារម៉ាកវិញទៀតសោត ក្នុងខណៈពេលអនុវត្តន៍កិច្ចការតំណាងរបស់ខ្លួន ចាំបាច់ត្រូវតែមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ផ្ទុយទៅវិញប្រសិនបើភ្នាក់ងារម៉ាកនោះពុំមានទីលំនៅ ឬមិនប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាប្រទេសកម្ពុជាទេនោះ មានន័យថាភ្នាក់ងារម៉ាកនោះនឹងបាត់បង់សិទ្ធិស្របច្បាប់ក្នុងការតំណាងឲ្យម្ចាស់ម៉ាកសម្រាប់កិច្ចការចុះបញ្ជី។ ម្យ៉ាងវិញទៀត តាមរយៈអត្ថន័យ នៃមាត្រាដដែល បានឆ្លុះបញ្ចាំងឲ្យឃើញថា ភ្នាក់ងារម៉ាកបរទេសពុំអាចអនុវត្តសិទ្ធិតំណាងរបស់ខ្លួនក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាបានឡើយ ព្រោះថាភ្នាក់ងារម៉ាកបរទេសនោះពុំមានទីលំនៅ និងមិនបានប្រកបអាជីវកម្មក្នុងប្រទេសកម្ពុជា។ ដោយឡែកចំពោះ**ទិដ្ឋភាពទីពីរ**វិញ បានបង្ហាញពីលក្ខខណ្ឌគ្រឹះ ដើម្បីក្លាយខ្លួនជាភ្នាក់ងារម៉ាកដែរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។ ត្រង់ចំនុចនេះបានលេចចេញជាចំណោទបញ្ហាត្រង់ថា តើអ្វីជាលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរមាននៅក្នុងប្រកាស? ហើយតើពេលណាបានប្រកាសនោះចេញមកអនុវត្តទៅ? តែទោះជាយ៉ាងណាក្នុងខណៈពេលដែរប្រកាសរបស់ក្រសួងពាណិជ្ជកម្មពុំទាន់ចេញ ការអនុវត្តតួនាទីរបស់ភ្នាក់ងារម៉ាកនៅតែបន្តកិច្ចការរបស់ខ្លួនដ៏ដែរ។

- អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពីនៃការប្រកួតប្រជែងមិនស្មោះត្រង់ លេខ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦។ គោលបំណងសំខាន់នៃអនុក្រឹត្យគឺកំណត់អំពី នីតិវិធីនៃការចុះបញ្ជីម៉ាក ការបដិសេធ ភ្នាក់ងារតំណាងម៉ាក ការប្រកាសសិទ្ធិអាទិភាព ការលុបម៉ាកចេញពីបញ្ជី និងវិធានការតាមមាត់ច្រកព្រំដែន។ ក្នុងនោះចំនុចសំខាន់នៃអនុក្រឹត្យដែរទាក់ទងនឹងភ្នាក់ងារម៉ាក បានស្តែងឲ្យឃើញលើពីរបរិបទរួមមាន៖ **បរិបទទីមួយ** បានរំលេចពីតួនាទីសំខាន់ៗរបស់ភ្នាក់ងារម៉ាកក្នុងដំណើរការចុះបញ្ជី និងការចូលរួមដោះស្រាយវិវាទម៉ាកផ្សេងៗ។ នៅក្នុងដំណើរការចុះបញ្ជី ភ្នាក់ងារម៉ាកត្រូវរៀបចំនិងបំពេញនូវរាល់ចំនុចសំខាន់នៃពាក្យស្នើសុំ ដោយក្នុងនោះអ្វីដែរមិនអាចខ្វះបានគឺ ឈ្មោះ អាសយដ្ឋានសញ្ជាតិ និងនិវេសនដ្ឋានរបស់ម្ចាស់ម៉ាករួមទាំងរបស់ភ្នាក់ងារតំណាងផងដែរ គំរូម៉ាកចំនួន១៥ (ស្ថិតក្នុងស្ថានភាពតែមួយ)...។ ក្នុងពេលជាមួយគ្នា ប្រសិនបើមានវិវាទអំពីម៉ាកកើតឡើង ទាំងមុននឹងក្រោយការប្រកាសផ្សាយ ភ្នាក់ងារម៉ាកបានចូលរួមយ៉ាងសំខាន់ក្នុងនីតិវិធីដោះស្រាយជម្លោះ។ ត្រង់ចំនុចនេះបានបង្ហាញឲ្យឃើញកាន់តែច្បាស់អំពីការការពារផលប្រយោជន៍របស់

ម្ចាស់ម៉ាក ប្រឆាំងទៅនឹងការរំលោភបំពានណាមួយ។ ដោយឡែកចំពោះ**បរិបទទីពីរវិញ** បានបង្ហាញអំពីលិខិតប្រគល់សិទ្ធិ[១៨] ដែលធ្វើឡើងដោយម្ចាស់ម៉ាកផ្ទាល់ ដើម្បីបញ្ជាក់អំពីភាពស្របច្បាប់ក្នុងអំពើនៃភ្នាក់ងារតំណាងរបស់ខ្លួន សម្រាប់ជាភស្តុតាងចំពោះមុខអាជ្ញាធរ។ សូមកត់សម្គាល់ផងដែរថា សុពលភាពនៃលិខិតប្រគល់សិទ្ធិមានរយៈពេល២ខែគិតតាំងចាប់ពីថ្ងៃចុះហត្ថលេខា។

- ប្រកាសស្តីពី នីតិវិធីរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា លេខ៣៦៨ ពណ.ពកប.ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ ។ ផ្នែកខ្លះនៃប្រកាសនេះបានចែងទាក់ទងនឹងតួនាទីភ្នាក់ងារម៉ាក ដែលទទួលបានសិទ្ធិតំណាងពីម្ចាស់ម៉ាក ត្រូវរាយការណ៍ទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា អំពីការប្រើប្រាស់ ឬមិនប្រើប្រាស់នូវពាណិជ្ជសញ្ញា ឬសេវាសញ្ញា នៅរៀងរាល់៥ឆ្នាំម្តង។ ហើយលទ្ធផលដែលកើតចេញពីការខកខានមិនរាយការណ៍ នឹងនាំឲ្យពាណិជ្ជសញ្ញា ឬសេវាសញ្ញានោះនឹងត្រូវលុបចេញពីបញ្ជី។

- ប្រកាសស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា លេខ០៤៥ Moc/SM2011 ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។ តាមរយៈប្រកាសនេះ បានបង្ហាញពីគោលគំនិត៣ចម្បងៗ ទាក់ទងនឹងភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។ ចំពោះ**គោលគំនិតទី១** សំដៅកំណត់នូវលក្ខខណ្ឌតម្រូវ និងនីតិវិធីទទួលស្គាល់បុគ្គលធ្វើជាតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ដោយឡែកចំពោះ**គោលគំនិតទី២** សំដៅគ្រប់គ្រង និងពង្រឹងសមត្ថភាពរបស់តំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដើម្បីសម្រួលដល់ការងារចុះបញ្ជី និងកិច្ចការដទៃទៀតដែលទាក់ទងនឹងម៉ាក និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឲ្យមានភាពរលូនប្រកបដោយប្រសិទ្ធភាពខ្ពស់។ និង**គោលគំនិតទី៣** សំដៅផ្តល់ភាពងាយស្រួលដល់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្ម និងការពារសិទ្ធិរបស់ខ្លួន តាមរយៈអ្នកតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

### ១.២.២. សារប្រយោជន៍នៃភ្នាក់ងារម៉ាកនៅក្នុងវិស័យម៉ាក

ជាងពីរទសវត្សមកហើយ ដែលប្រទេសកម្ពុជាបាននឹងកំពុងអនុវត្តប្រព័ន្ធចុះបញ្ជីម៉ាក។ ក្នុងនោះវត្តមានភ្នាក់ងារម៉ាកបានដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការស្នើសុំចុះបញ្ជីម៉ាកនៅកម្ពុជា។ ការចូលរួមកិច្ចអនុវត្តន៍ច្បាប់របស់ភ្នាក់ងារម៉ាក បានធ្វើឲ្យមានសន្ទុះកើនឡើងខ្លាំងនូវម៉ាកដែរទទួលបានការ

[១៨] ក្នុងប្រព័ន្ធកម្មសិទ្ធិបញ្ញា លិខិទប្រគល់សិទ្ធិមានពីរប្រភេទ គឺលិខខិតប្រគល់សិទ្ធិទូទៅ (Giving full power to legal Attorney /Agent) និងលិខិតប្រគល់សិទ្ធិដោយកម្រិត(Giving less power to legal Attorney/Agent) ។ ដើម្បីទទួលបានឯកសារលំអិត សូមចូលទៅកាន់គេហទំព័រ៖ www.wipo.int/pct/en/texts/rules/r90.html#_90_4_a ។

យល់ព្រមចុះបញ្ជីជូន។ ក្នុងពេលជាមួយគ្នា ភ្នាក់ងារម៉ាកក៏បានចូលរួមចំណែកក្នុងការផ្សព្វផ្សាយច្បាប់ជូនដល់ប្រជាពលរដ្ឋទូទៅដែលជាអតិថិជនរបស់ខ្លួន។ ដោយសារមានការរួមសហការគ្នារវាងតួអង្គរដ្ឋ និងភ្នាក់ងារម៉ាក បានធ្វើឲ្យប្រជាពលរដ្ឋទូទៅងាកមកចាប់អារម្មណ៍លើម៉ាកសញ្ញាសម្រាប់ប្រើប្រាស់លើទំនិញឬសេវារបស់ខ្លួន។ ក្នុងន័យដើម្បីទទួលបានកិច្ចការពារដោយស្របច្បាប់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។ ជាលទ្ធផលនៃការអនុវត្តតួនាទីក្នុងឋានៈជាភ្នាក់ងារម៉ាក នារយៈពេលកន្លងមកនេះបានផ្តល់ផលប្រយោជន៍ដល់គោលដៅ៣ចម្បងៗ ដូចជា៖

គោលដៅចម្បងទី១គឺ **ផលប្រយោជន៍សម្រាប់ម្ចាស់ម៉ាក** ៖ តាមរយៈការផ្ទេរសិទ្ធិទៅឲ្យភ្នាក់ងារម៉ាក ដើម្បីជួយដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ម្ចាស់ម៉ាកបានកាត់បន្ថយនូវបន្ទុកនៃភាពស្មុគស្មាញក្នុងដំណើរការនៃនីតិវិធីចុះបញ្ជីម៉ាក ចំណេញពេលវេលាសម្រាប់អនុវត្តកិច្ចជំនួញផ្សេងទៀតរបស់ខ្លួន ហើយនេះគឺជាឱកាសសម្រាប់សម្លឹងរកទីផ្សារផ្សេងទៀតដើម្បីប្រកួតប្រជែង។ ជាមួយគ្នានេះដែរ ម្ចាស់ម៉ាកនឹងមានភាពច្បាស់លាស់ក្នុងការចំណាយថវិកា ជាមួយភ្នាក់ងារក្នុងតម្លៃនៃការចរចាគ្នាប្រកបដោយភាពស្មើភាពគ្នា។ ស្របពេលជាមួយគ្នាម្ចាស់ម៉ាកនឹងទទួលបានព័ត៌មានពាក់ព័ន្ធនឹងម៉ាករបស់ខ្លួន ម៉ាកដែលមានលក្ខណៈប្រហាក់ប្រហែល ឬស្រដៀងជាដើម គួបផ្សំនឹងការវិភាគគ្រប់ជ្រុងជ្រោយដោយយោងលើទិដ្ឋភាពលំអិតនៃច្បាប់ សម្រាប់ធ្វើជាមូលដ្ឋានគ្រឹះក្នុងការពិចារណា ប្រកបដោយភាពច្បាស់លាស់ក្នុងការស្នើសុំចុះបញ្ជី។ ក្នុងពេលជាមួយគ្នានេះដែរ ម្ចាស់ម៉ាកនឹងមិនក្លាយជាជនរងគ្រោះដោយសារអំពើពុករលួយឡើយ ព្រោះថាម្ចាស់ម៉ាកបានយល់ដឹងច្បាស់ពីមូលដ្ឋានច្បាប់រួចទៅហើយ។

ចំនុចដែលសំខាន់របស់ម្ចាស់ម៉ាកក្នុងការប្រើប្រាស់ភ្នាក់ងារម៉ាក គឺដើម្បីឆាប់ទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក និងហាមឃាត់តតិយជនពីការប្រើប្រាស់ ឬរំលោភបំពានម៉ាក និងទំនិញក្លែងបន្លំម៉ាករបស់ខ្លួនតាមគ្រប់រូបភាព ដោយគ្មានការអនុញ្ញាតជាមុនពីម្ចាស់ម៉ាក។ ក្នុងន័យនេះតាមរយៈការចុះបញ្ជី ម៉ាកមួយនឹងទទួលបាននូវកិច្ចការពារស្របច្បាប់នៅកម្ពុជាក្នុងរយៈពេលកំណត់ដោយច្បាប់[៩] ។ ក្នុងន័យម្យ៉ាងទៀត ម្ចាស់ម៉ាកអនុវត្តន៍ដោយងាយស្រួលនូវសិទ្ធិរបស់ខ្លួនសម្រាប់សកម្មភាពសេដ្ឋកិច្ចក្នុងការធ្វើអាជីវកម្មតាមគ្រប់រូបភាព និងសិទ្ធិក្នុងការផលិតឡើងវិញនូវម៉ាករបស់ខ្លួនលើទំនិញ ឬសេវាស្របតាមប្រភេទនៃទំនិញ ឬសេវាដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី។ បន្ថែមលើសពីនេះ ដោយហេតុថាម៉ាកជាទ្រព្យអរូបិយ ម្ចាស់ម៉ាកអាចយកទ្រព្យនេះទៅដាក់បញ្ចាំ ដើម្បីទទួលបាននូវ

---

[៩] រយៈពេលកំណត់ដោយច្បាប់សម្រាប់កិច្ចការពារម្ចាស់ម៉ាកក្នុងការប្រើប្រាស់សិទ្ធិផ្តាច់មុខ មានរយៈពេល១០ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក។ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា១២,ចំនុច ក(ពីពេលនេះតទៅហៅថា ច្បាប់ម៉ាក) ។ សូមបញ្ជាក់ផងដែរថា ការដែរកម្ពុជាកំណត់រយៈ១០ឆ្នាំនេះ គឺស្របនឹងកិច្ចព្រមព្រៀងTRIPS ដែលតម្រូវឲ្យរដ្ឋសមាជិកនីមួយៗកំនត់នូវរយៈពេលជាក់លាក់នៃកិច្ចការពារម៉ាកនៅក្នុងច្បាប់ជាតិរបស់ខ្លួន ដែលមានរយៈពេលយ៉ាងតិច ៧(ប្រាំពីរ)ឆ្នាំ។ បទប្បញ្ញត្តិនេះមានន័យថា រយៈពេលសុពលភាពនៃម៉ាកអាចត្រូវបានកំណត់ដោយច្បាប់ជាតិចាប់ពី៧ (ប្រាំពីរ) ឆ្នាំឡើងទៅ ហើយអាចចុះបញ្ជីសារជាថ្មីបាន។ជាទូទៅ រយៈពេលនៃកិច្ចការពារម៉ាកក្នុងបណ្តាលប្រទេសទាំងឡាយនៅលើពិភពលោកគឺ ១០(ដប់) ឆ្នាំ។

ដើមទុនក្នុងការពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ពាណិជ្ជកម្ម ក៏ដូចជាអាចធ្វើជាមូលនិធិពាណិជ្ជកម្មសម្រាប់សហគ្រាស[២០]ផងដែរ។ ជារួមតាមរយៈសិទ្ធិផ្ដាច់មុខ បានធ្វើឲ្យម្ចាស់ម៉ាកមានភាពកក់ក្ដៅប្រកបដោយទំនុកចិត្តខ្ពស់ក្នុងការបង្កើនកម្រិតវិនិយោគរបស់ខ្លួនឲ្យកាន់តែរីកចម្រើនឡើង។ ហើយវាអាចកើតមានបានតាមរយៈកម្រិតអនុវត្តច្បាប់ខ្ពស់របស់អាជ្ញាធរមានសមត្ថកិច្ច។

គោលដៅចម្បងទីពីរគឺ **ផលប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ** ៖ ដោយសារវិស័យម៉ាករីកចម្រើនបានជំរុញឲ្យមានទំហំនៃការវិនិយោគចូលមកក្នុងប្រទេសកម្ពុជាកាន់តែច្រើនឡើង ជាហេតុធ្វើឲ្យមានតម្រូវការកម្លាំងពលកម្មកាន់តែខ្ពស់ សម្រាប់បម្រើដល់សង្វាក់ផលិតកម្ម។ នេះគឺជាឱកាសការងារសម្រាប់ប្រជាជនប្រកបដោយសុវត្ថិភាព ដោយពុំចាំបាច់ប្រថុយប្រថានចំណាកស្រុកដើម្បីរកការងារធ្វើនៅក្រៅប្រទេសឡើយ។ ឱកាសការងារនេះបានបង្កើតឲ្យមានភាពរីកចម្រើនដល់កម្រិតជីវភាពរបស់ប្រជាជននៅតាមទីជនបទ ដោយកម្លាំងដែលបម្រើដល់ការអភិវឌ្ឍវិស័យពាណិជ្ជកម្មម៉ាកគឺបានមកពីវត្តមានរបស់ប្រជាពលរដ្ឋនៅតាមទីជនបទនេះឯង។ ដោយសារផលិតកម្មនៃវិស័យម៉ាកក្នុងប្រទេសកើនឡើង បានធ្វើឲ្យប្រជាពលរដ្ឋទូទៅមានលទ្ធភាពប្រើប្រាស់ផលិតផលប្រកបដោយគុណភាព និងការទទួលខុសត្រូវហើយផលដែលកើតចេញពីការប្រើប្រាស់នោះ គឺយើងអាចធានាបាននូវសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋ។

ការវិនិយោគវិស័យម៉ាកក្នុងប្រទេសជាផ្នែកមួយនៃការផ្ទេរចំណេះនិងជំនាញ ក៏ដូចជាបច្ចេកទេសក្នុងការផលិតនូវផលិតផលដែលមានបំពាក់ម៉ាកសញ្ញា។ តាមរយៈការផ្ទេរចំណេះជំនាញ បានធ្វើឲ្យប្រជាពលរដ្ឋស្គាល់អំពីតម្លៃនៃការជ្រើសរើសម៉ាកយកមកប្រើប្រាស់ សម្រាប់បំពាក់លើទំនិញ ឬសេវារបស់ខ្លួន និងជាពិសេសអត្ថប្រយោជន៍នៃការចុះបញ្ជីម៉ាក។

គោលដៅចម្បងទីបី គឺ **ផលប្រយោជន៍សម្រាប់ប្រទេសជាតិ** ៖ ដោយសម្រេចបានដោយជោគជ័យនូវប្រព័ន្ធចុះបញ្ជីម៉ាក និងការអនុវត្តច្បាប់ស្របតាមបទដ្ឋានអន្តរជាតិ បានទាក់ទាញវិនិយោគទុនជាម្ចាស់ម៉ាក មកបណ្ដាក់ទុនរកស៊ីនៅកម្ពុជាកាន់តែប្រសើរ។ លទ្ធផលនេះបានស្ដែងឲ្យឃើញតាមរយៈពាក្យស្នើសុំចុះបញ្ជីម៉ាក គ្រាន់តែដើមឆ្នាំ២០១៧ មានពាក្យស្នើសុំចំនួន៣១៧៤ម៉ាក[២១] ក្នុងនោះម៉ាកដែលបានទទួលការអនុញ្ញាចុះបញ្ជីមាន២៦៤២ម៉ាក។ ទាញចេញពីទិន្នន័យនេះ ឆ្លុះបញ្ចាំងឲ្យឃើញទិដ្ឋភាពពីរយ៉ាងរួមមាន៖ ប្រសិទ្ធភាពក្នុងការវិនិច្ឆ័យរបស់មន្ត្រីកាន់កាប់បញ្ជី និង ការប្រមូលចំណូលចូលរដ្ឋ។

ចំពោះប្រសិទ្ធភាពការងាររបស់មន្ត្រីកាន់កាប់បញ្ជី អាចប្រសើរទៅបានក៏អាស្រ័យលើការចូលរួមសហការរបស់ភ្នាក់ងារម៉ាកក្នុងដំណើរការស្នើសុំចុះបញ្ជី។ ព្រោះភ្នាក់ងារជាបុគ្គលដែលតំណាងឲ្យ

[២០] សូមបញ្ជាក់ផងដែរថា គិតមកដល់ពេលបច្ចុប្បន្ននេះ យើងពុំឃើញមានការអនុវត្តណាមួយនៅក្នុងវិស័យធនាគារដែលទទួលយកទ្រព្យកម្មសិទ្ធបញ្ញា ធ្វើជាវត្ថុធានាក្នុងការអនុវត្តកាតព្វកិច្ចសងបំណុលក្នុងកិច្ចសន្យាកម្ចីប្រាក់ពីធានាគារនៅកម្ពុជានៅឡើយទេ។

[២១] គំណរភ្ជាប់សម្រាប់ព័ត៌លំអិតទាក់ទងនឹងទិន្នន័យនៃការចុះបញ្ជីម៉ាកនៅកម្ពុជា៖ www.wipo.int/branddb/kh/en/

ម្ចាស់ម៉ាកប្រកបដោយលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រមជាមួយនឹងចំណេះជំនាញច្បាស់លាស់ក្នុងកិច្ចការស្នើសុំចុះបញ្ជីម៉ាក។ ដោយសារតែលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ភ្នាក់ងារម៉ាកនេះ បានផ្តល់ភាពងាយស្រួលដល់មន្ត្រីត្រួតពិនិត្យម៉ាក(ទាំងទម្រង់ និងខ្លឹមសារ) ប្រកបដោយភាពឆាប់រហ័ស និងច្បាស់លាស់។

ដោយឡែកចំពោះការប្រមូលចំណូលចូលរដ្ឋ ក៏បានឆ្លុះបញ្ចាំងតាមរយៈការបង់កម្រៃចុះបញ្ជីពីសំណាក់អ្នកដាក់ពាក្យស្នើសុំ។ ដូចដឹងស្រាប់ហើយថា កម្រៃដែលបានមកពីការចុះបញ្ជីវា ជាប្រភពចំណូលដ៏សំខាន់របស់ទ្រទ្រង់ដង្ហើមសេដ្ឋកិច្ចជាតិ និងសម្រាប់យកទៅអភិវឌ្ឍន៍ប្រទេសទៅតាមតម្រូវការចាំបាច់ចំពោះមុខស្របតាមគោលនយោបាយជាតិ។

ម៉្យាងទៀតវត្តមានភ្នាក់ងារម៉ាកបានជួយពន្លឿន ដល់ដំណើរការដោះស្រាយវិវាទនានា ដែលកើតមានឡើងទាំងមុនពេលប្រកាសផ្សាយ និងក្រោយពេលប្រកាសផ្សាយជាអាទិ៍ ពីព្រោះភ្នាក់ងារម៉ាកក្នុងដំណើរការចុះបញ្ជី ត្រូវបានចាត់ទុកដូចជាម្ចាស់ម៉ាកដោយប្រយោល។ ការចូលរួមរបស់ភ្នាក់ងារម៉ាកនឹងមានភាពងាយស្រួល ហើយឆាប់រហ័ស ដើម្បីឈានដល់ការបញ្ចប់ជម្លោះនានា ព្រោះភ្នាក់ងារម៉ាកយល់ដឹងពីច្បាប់ និងនីតិវិធីបានច្បាស់។ ជាលទ្ធផលក្នុងពេលកន្លងមក វិស័យម៉ាកបានទទួលការកោតសរសើរពីសំណាក់វិនិយោគិនបរទេស ក្នុងការអនុវត្តច្បាប់ម៉ាកប្រកបដោយភាពច្បាស់លាស់ និងតម្លាភាព។ នេះជាសញ្ញាណវិជ្ជមានដ៏ល្អមួយ ដែលបានជួយលើមុខមាត់ជាតិក្នុងឆាកអន្តរជាតិក៏ជាផ្នែកមួយក្នុងការបន្តទាក់ទាញវិនិយោគមកក្នុងប្រទេសឲ្យកាន់តែច្រើនបន្ថែមទៀត។

# ជំពូកទី ២

## ក្របខណ្ឌគុណវុឌ្ឍិ និង សមត្ថកិច្ចរបស់ភ្នាក់ងារម៉ាក

ភ្នាក់ងារម៉ាកគឺជាបុគ្គលដែលសំខាន់សម្រាប់ជាជំនួយដល់ម្ចាស់ម៉ាកក្នុងដំណើរការចុះបញ្ជី។ ឬអាចនិយាយបានមួយបែបទៀតថា ភ្នាក់ងារម៉ាកគឺជាកម្លាំងចលករដ៏ចាំបាច់ និង មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍវិស័យម៉ាក កិច្ចការពារ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ដោយមើលឃើញពីតម្រូវការចំពោះមុខ ទើបនៅឆ្នាំ២០០២ ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ត្រូវបានព្រះមហាក្សត្រឡាយព្រះហត្ថលេខាប្រកាសឲ្យអនុវត្តន៍។ ក្នុងនោះច្បាប់បានចែងទទួលស្គាល់ពីតួនាទីរបស់ភ្នាក់ងារម៉ាក សម្រាប់តំណាងឲ្យម្ចាស់ម៉ាកបរទេស ក្នុងដំណើរការស្នើសុំចុះបញ្ជីម៉ាក។ ក៏ប៉ុន្តែអ្វីដែលជាកង្វះខាតនៃច្បាប់គឺ ពុំបានចែងច្បាស់អំពីលក្ខខណ្ឌដើម្បីទទួលបានលក្ខណៈសម្បត្តិគតិយុត្តនៃភ្នាក់ងារម៉ាកឡើយ។ ពិតណាស់ក្នុងឋានៈជាអ្នកតំណាងសិទ្ធិឲ្យម្ចាស់ម៉ាក ចាំបាច់ត្រូវទាមទារឲ្យមានលក្ខណៈគុណវុឌ្ឍិច្បាស់លាស់មួយ ដើម្បីបំពេញលក្ខខណ្ឌសុពលភាពនៃកិច្ចអនុវត្តន៍របស់ខ្លួន។ បើមិនដូច្នោះទេ តើធ្វើយ៉ាងណាអាចសម្រេចបានការអភិវឌ្ឍវិស័យកម្មសិទ្ធិបញ្ញា សម្រាប់ម៉ាកបរទេសដោយជោគជ័យកើត? ខណៈពេលដែរច្បាប់ចែងតែពីតួនាទី តែពុំបានចែងពីនីតិវិធីដើម្បីទទួលបានលក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាកឲ្យនោះ។

ក្រោយមកនៅឆ្នាំ២០១១ ទើបយើងឃើញមានបទដ្ឋានបំពេញបន្ថែមនៃច្បាប់ ដោយក្រសួងពាណិជ្ជកម្មបានចេញ ប្រកាសមួយស្ដីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១១។ តាមរយៈបទដ្ឋាននេះហើយ ដែលបានបង្ហាញពីនីតិវិធីទទួលបានលក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក និងបង្ហាញពីសមត្ថកិច្ចរបស់ភ្នាក់ងារម៉ាកផងដែរនៅក្នុងវិស័យម៉ាក។

ផ្ដើមចេញពីប្រកាសខាងលើនេះហើយ ទើបនៅឆ្នាំ២០១២ ក្រសួងពាណិជ្ជកម្មបានរៀបចំឲ្យមានវគ្គបណ្ដុះបណ្ដាលភ្នាក់ងារម៉ាកជំនាន់ទី១ឡើង។ ក្នុងពេលចាប់ផ្ដើមដំបូងក្រសួងសម្រេចជ្រើសយកបេក្ខជនចំនួន ៣៧នាក់ឲ្យចូលរៀន ដោយក្នុងនោះមានបេក្ខជនចំនួន៣៤នាក់ប្រឡងជាប់ជាស្ថាពរ និង២នាក់ប្រឡងធ្លាក់ និង១នាក់ទៀតបោះបង់សិទ្ធិក្នុងការប្រឡង។ តាមរយៈលទ្ធផលនៃការជ្រើសរើសនេះ គឺដើម្បីបំពេញការងារជំនួសភ្នាក់ងារម៉ាកដែរមានស្រាប់[២២]ឲ្យស្របតាមនីតិវិធីរបស់ប្រកាស។

ដូច្នេះក្នុងជំពូកនេះនឹងចង្អុលបង្ហាញអំពីសមត្ថកិច្ចតាមផ្លូវច្បាប់របស់ភ្នាក់ងារម៉ាក(២.២) បន្ទាប់ពីយើងបានសិក្សាអំពីលក្ខខណ្ឌខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាករួចមក(២.១)។

[២២] ភ្នាក់ងារម៉ាកដែលកើតមានមុនប្រកាសទាំងអស់ ឬហៅម្យ៉ាងទៀតថាជាភ្នាក់ងារម៉ាកដែរមានស្រាប់ មានរយៈពេល៥(ប្រាំ)ឆ្នាំសម្រាប់បំពេញលក្ខណៈសម្បត្តិគ្រប់គ្រាន់អោយស្របតាមការកំណត់របស់ច្បាប់ ក៏ដូចជាប្រកាស។ ប្រកាសស្ដីពីភ្នាក់ងារម៉ាក,ប្រការ២៨។

## ២.១.លក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក

គ្រប់សកម្មភាពគតិយុត្តិទាំងអស់របស់ភ្នាក់ងារម៉ាក អាចប្រព្រឹត្តទៅបានអាស្រ័យដោយច្បាប់ ឬបទដ្ឋានគតិយុត្តិបានផ្ដល់ឲ្យ។ ការផ្ដល់នូវអំណាចគតិយុត្តិនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីតម្លៃនៃវិសាលភាពការងារប្រតិបត្តិរបស់ភ្នាក់ងារម៉ាក។ ម៉្យាងវិញទៀតស្ថានភាពខាងលើ ក៏បានឆ្លុះបញ្ចាំងឲ្យឃើញពីគុណវុឌ្ឍិរបស់ភ្នាក់ងារម៉ាកក្នុងវិស័យម៉ាកផងដែរ។ ហេតុដូចនេះហើយបានជាយើង ចាំបាច់ត្រូវសិក្សាអំពីយន្តការដើម្បីទទួលបានគុណវុឌ្ឍិជាភ្នាក់ងារម៉ាក(២.១.១) ហើយក៏ត្រូវយល់ដឹងផលដែរអំពី មូលហេតុនៃការបាត់បង់លក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក(២.១.២)។

តើមានមូលហេតុអ្វីខ្លះដែលអាចទទួលបានលក្ខខណ្ឌគុណវុឌ្ឍិក្លាយជាភ្នាក់ងារម៉ាក?

### ២.១.១ យន្តការដើម្បីទទួលបានគុណវុឌ្ឍិជាភ្នាក់ងារម៉ាក

ការទទួលបានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាភ្នាក់ងារម៉ាក ចាំបាច់ត្រូវឆ្លងកាត់ការប្រឡងប្រជែងសមត្ថភាពដើម្បីអាចបំពេញលក្ខខណ្ឌគ្រឹះ នៃការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម។ នេះសបញ្ជាក់ឲ្យឃើញថា ការយកដើមទុននៃចំណេះដឹងរបស់អ្នកដែលមានបំណងធ្វើជាភ្នាក់ងារម៉ាក ទៅប្រកួតប្រជែងគឺ ទាមទារឲ្យបុគ្គលនោះត្រូវមានចំណេះដឹងទូលាយពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ប្រកបដោយភាពច្បាស់លាស់ ឆ្លាតវៃ គួបផ្សំជាមួយនឹងបច្ចេកទេសសរសេរនិងបច្ចេកទេសនិយាយផងដែរ។ ពិតណាស់ថាការប្រឡងគឺជាលក្ខខណ្ឌគ្រឹះក៏ពិតមែន តែប្រសិនបើបេក្ខជនមិនបានចូលរៀនវគ្គបណ្ដុះបណ្ដាលត្រៀមប្រឡង ដែលរៀបចំដោយក្រសួងពាណិជ្ជកម្មទេនោះ ប្រាកដជាបាត់បង់សិទ្ធិ[២៣]ក្នុងការប្រឡងជាក់ជាពុំខាន។ គួរបញ្ជាក់ដែរថា មានអញ្ញត្រកម្មពីរយ៉ាងនៃករណីខាងលើ ក្នុងនោះៈ អញ្ញត្រកម្មទី១ គឺមានបុគ្គលមួយចំនួនដែរមានសិទ្ធិប្រឡង ដោយពុំចាំបាច់ឆ្លងកាត់វគ្គបណ្ដុះបណ្ដាលត្រៀម និងអញ្ញត្រកម្មទី២គឺ មានបុគ្គលមួយប្រភេទទៀត ទទួលបានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាភ្នាក់ងារម៉ាកដោយពុំចាំបាច់ឆ្លងកាត់វគ្គបណ្ដុះបណ្ដាលនឹងវគ្គប្រឡងឡើយ។

ដោយហេតុនេះ យើងនឹងសិក្សាបន្ថែមអំពីនីតិវិធីដើម្បីអាចទទួលបានសិទ្ធិចូលប្រឡងប្រជែង (២.១.១.១) និងបន្ទាប់ទៀតយើងនឹងសិក្សាអំពីនីតិវិធីទទួលលក្ខខណ្ឌគុណវុឌ្ឍិដោយស្វ័យប្រវត្តិ(២.១.១.២)។

#### ២.១.១.១. ការទទួលបានតាមរយៈការប្រកួតប្រជែង

ជាគោលការណ៍ ដើម្បីទទួលបានឋានៈជាភ្នាក់ងារម៉ាកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចាំបាច់បេក្ខជន ត្រូវជាប់ក្នុងវគ្គប្រឡងប្រជែង ហើយដើម្បីអាចចូលរួមវគ្គប្រឡងប្រជែង ទាមទារឲ្យ

[២៣] ប្រកាសស្ដីពីភ្នាក់ងារម៉ាក,ប្រការ២១,ចំនុច១ "បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបញ្ចប់វគ្គបណ្ដុះបណ្ដាលត្រៀម មុនកាលបរិច្ឆេទប្រឡងដែលបានធ្វើឡើងនៅចន្លោះពេលទៀងទាត់មួយ ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។"

គោរពតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ជាមុន។ តើអ្វីជាលក្ខខណ្ឌតម្រូវ ដើម្បីអាចចូលរួមវគ្គប្រឡងបាន?

**វគ្គបណ្តុះបណ្តាលត្រៀមប្រឡង៖** គឺជាមធ្យោបាយមួយ ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់បេក្ខជនសម្រាប់ត្រៀមលក្ខណៈមុនការប្រឡងប្រជែង។ ហើយវគ្គនេះបង្កើតឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពចំណេះដឹងរបស់បេក្ខជនពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា។ ដើម្បីអាចសម្រេចបាននូវគោលបំណងខាងលើ ទាមទារជាចាំបាច់ឲ្យបេក្ខជនត្រូវគោរពតាមលក្ខខណ្ឌតម្រូវរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដូចជា៖ ក.បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដោយមានបញ្ជាក់ភាពត្រឹមត្រូវ។ ខ.បេក្ខជនត្រូវដាក់ពាក្យស្នើសុំ និងបង់ថ្លៃចូលរៀនតាមការកំណត់របស់ក្រុមប្រឹក្សាប្រឡង ដើម្បីសម្រួលដល់ការចំណាយចាំបាច់នានា។ គ.មន្ត្រីរបស់ក្រសួងពាណិជ្ជកម្មត្រូវបានលើកលែងក្នុងការបង់ថ្លៃចូលរៀន។

បន្ទាប់ពីបំពេញបានលក្ខណៈខាងលើរួចហើយ បេក្ខជនដែលចូលរៀនវគ្គបណ្តុះបណ្តាលត្រូវឆ្លងការកម្មវិធីសិក្សាដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម រួមមាន៖ ក.ត្រូវសិក្សាមេរៀនទាក់ទងនឹងសញ្ញាណជាមូលដ្ឋាននៃកម្មសិទ្ធិបញ្ញា។ ខ.ច្បាប់កម្មសិទ្ធិបញ្ញាដែលរួមមាន ៖ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ , ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ, ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ រួមទាំងបទប្បញ្ញត្តិនានាដែលទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញា។ គ.ច្បាប់កម្ពុជាដទៃទៀតដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍របស់ភ្នាក់ងារតំណាងស្របច្បាប់។ ឃ.កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍ការងាររបស់ភ្នាក់ងារតំណាងស្របច្បាប់។ ង.ការអនុវត្តន៍ជាក់ស្តែងក្នុងការចុះបញ្ជី ការប្តឹងជំទាស់ និងដោះស្រាយវិវាទកម្មសិទ្ធិបញ្ញា។

ទន្ទឹមនឹងត្រូវទទួលការបណ្តុះបណ្តាលវគ្គត្រៀមប្រឡង ច្បាប់ក៏បានចែងអំពីអញ្ញត្រកម្មនៃវគ្គរៀនត្រៀមប្រឡងផងដែរ។ បន្ទាប់មកទៀត នៅចំនុចបន្ទាប់យើងនឹងសិក្សាលើករណីលើកលែងចំពោះការរៀនវគ្គបណ្តុះបណ្តាល។

### ករណីលើកលែងរៀនវគ្គបណ្តុះបណ្តាលត្រៀម

អនុលោមតាមប្រការ២១នៃប្រកាសស្តីពីភ្នាក់ងារម៉ាក បានចែងការលើកលែកសម្រាប់វគ្គត្រៀមបណ្តុះបណ្តាលប្រឡង ឲ្យដល់បុគ្គលពីរប្រភេទរួមមាន៖ ក. មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានបម្រើការងារយ៉ាងតិច ០៥ឆ្នាំ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។ ខ. បេក្ខជនទាំងឡាយដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញកម្មសិទ្ធិបញ្ញា ឬខ្ពស់ជាង ដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច និងមានបទពិសោធន៍ក្នុងការងារកម្មសិទ្ធិបញ្ញាចំនួន ០៥ឆ្នាំយ៉ាងតិចនៅក្នុងភ្នាក់ងារកម្មសិទ្ធិបញ្ញា ឬក្រុមហ៊ុនច្បាប់ ឬក្នុងការិយាល័យដែលទទួលបន្ទុកកម្មសិទ្ធិបញ្ញានៃក្រុមហ៊ុនណាមួយ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។

ជារួមតាមរយៈលក្ខខណ្ឌទាំងពីរខាងលើ យើងអាចយល់បានថា ដើម្បីអាចទទួលបានការអនុគ្រោះដោយពុំចាំបាច់រៀនវគ្គត្រៀមប្រឡង ទាមទារឲ្យបេក្ខជនត្រូវមានលក្ខណៈសម្បត្តិតម្រូវមួយចំនួនផងដែរ។ ដូចបានបញ្ជាក់នៅខាងលើរួចមកហើយថា គោលគំនិតនៃការបង្កើតវគ្គបណ្តុះបណ្តាលគឺ ដើម្បីពង្រឹង និងពង្រីកចំណេះដឹងរបស់បេ្ខជនប្រឡង ឲ្យកាន់តែច្បាស់លាស់បន្ថែមទៀតចំពោះវិស័យកម្មសិទ្ធិបញ្ញា។ ផ្ទុយទៅវិញប្រសិនបើបុគ្គលដែរត្រូវលើកលែងនោះពុំមានចំណេះដឹងច្បាស់លាស់ទាក់ទង់នឹងវិស័យកម្មសិទ្ធិបញ្ញាទេ តើធ្វើយ៉ាងនឹងអាចជាប់វគ្គប្រឡងទៅ? សរុបមកដោយសារហេតុផលទាំងនេះហើយ បានជាអ្នកនីតិនិពន្ធបានលើកយកករណីលើកលែងចំពោះការរៀនត្រៀមប្រឡងមកធ្វើជាអញ្ញតកម្ម។

**វគ្គប្រឡងប្រជែង[24]៖** ការប្រឡងប្រជែងគឺ ជាផ្លូវតែមួយគត់ដើម្បីអាចឈានទៅបំពេញលក្ខខណ្ឌគ្រឹះ ក្នុងការទទួលបានគុណវុឌ្ឍិជាភ្នាក់ងារម៉ាក។ ប៉ុន្តែដើម្បីឈានមកដល់ការប្រឡងបានទាមទារឲ្យបេក្ខជនត្រូវបំពេញលក្ខខណ្ឌចុះឈ្មោះប្រឡង រួមមាន៖ ក.បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀម មុនកាលបរិច្ឆេទប្រឡងដែលបានរៀបចំឡើងនៅចន្លោះពេលទៀងទាត់មួយ ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។ ខ.មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានបម្រើការងារយ៉ាងតិច៥ឆ្នាំ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។ គ.បេក្ខជនទាំងឡាយដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញកម្មសិទ្ធិបញ្ញា ឬខ្ពស់ជាង ដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច និងមានបទពិសោធន៍ក្នុងការងារកម្មសិទ្ធិបញ្ញាចំនួន៥ឆ្នាំយ៉ាងតិចនៅក្នុងភ្នាក់ងារកម្មសិទ្ធិបញ្ញា ឬក្រុមហ៊ុនច្បាប់ ឬក្នុងការិយាល័យដែលទទួលបន្ទុកកម្មសិទ្ធិបញ្ញានៃក្រុមហ៊ុនណាមួយ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។ ឃ.បេក្ខជនត្រូវជាវពាក្យស្នើសុំចុះឈ្មោះប្រឡង។ ក្រុមប្រឹក្សាប្រឡងជាអ្នកកំណត់តម្លៃពាក្យស្នើសុំចុះឈ្មោះប្រឡងដើម្បីមានថវិការទ្រទ្រង់ការចំណាយចាំបាច់នានាក្នុងដំណើរការប្រឡង។ ង.មន្ត្រីនៃក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និងលេខាធិការដ្ឋាន ដែលកំពុងកាន់មុខតំណែងមិនមានសិទ្ធិចុះឈ្មោះប្រឡងទេ។ មន្ត្រីទាំងនោះនឹងមានសិទ្ធិចុះឈ្មោះប្រឡង បន្ទាប់ពីតំណែងរបស់ខ្លួនត្រូវបានបញ្ចប់។

បន្ទាប់ពីបំពេញបាននូវលក្ខខណ្ឌតម្រូវរួមហើយ បេក្ខជនត្រូវប្រឡងលើវិញ្ញាសារសរសេរ និងឬផ្ទាល់មាត់។ វិញ្ញាសាសរសេរដែរបេក្ខជនត្រូវប្រឡងរួមមាន៖ ក. មេរៀនទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញារួមមាន៖ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ , ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ, ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ រួមទាំងបទប្បញ្ញត្តិនានាដែលទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញា និងច្បាប់កម្ពុជាដ៏ទៃទៀតដែលត្រូវបានចាត់ទុកដោយក្រុម

[24] ប្រកាសស្តីពីភ្នាក់ងារម៉ាក,ប្រការ២១

ប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍។ ខ. ច្បាប់អន្តរជាតិទាំងឡាយពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ហើយដែរកម្ពុជាផ្តល់សច្ចាប័ណ្ណ រួមមាន៖ កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍។

សរុបមកបន្ទាប់ពីបេក្ខជនបំពេញបានតាមរាល់លក្ខខណ្ឌតម្រូវរួចមក នឹងបន្ទាប់ពីបានប្រឡងជាប់ជាស្ថាពរហើយ បេក្ខជននឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក[២៥]ពីក្រសួងពាណិជ្ជកម្ម។ បន្ថែមលើពីនេះ ក្នុងករណីដែលភ្នាក់ងារម៉ាកឈរឈ្មោះតំណាងឲ្យនីតិបុគ្គលណាមួយនោះ ភ្នាក់ងារម៉ាកត្រូវដាក់ពាក្យស្នើសុំការទទួលស្គាលជាមុនពីក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របញ្ជាក់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក[២៦]។ បន្ទាប់មកក្រសួងពាណិជ្ជកម្ម និងចេញវិញ្ញាបនបត្រទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

#### ២.១.១.២. ទទួលបានដោយស្វ័យប្រវត្តិ

ជាគោលការណ៍ដើម្បីទទួលបានលក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក ចាំបាច់តម្រូវឲ្យបេក្ខជនត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលត្រៀមប្រឡង និងជាប់វគ្គប្រឡងជាមុន។ ក៏ប៉ុន្តែជាអញ្ញត្រកម្មនៃគោលការណ៍ខាងលើនេះ ច្បាប់ក៏បានចែងអំពីលក្ខខណ្ឌទទួលបានគុណវុឌ្ឍិជាភ្នាក់ងារម៉ាក។ លក្ខខណ្ឌនៃអញ្ញត្រកម្មមានជាអាទ៍៖ ក. អ្នកត្រួតពិនិត្យខ្លឹមសារម៉ាកលម្អិត ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិចចំនួន០៦ឆ្នាំ។ នេះសបញ្ជាក់ឲ្យឃើញថា មានតែមន្ត្រីរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាទេដែលអាចបំពេញលក្ខខណ្ឌតម្រូវនៃច្បាប់។ ព្រោះថា គ្មានបុគ្គលណាមួយអាចត្រួតពិនិត្យម៉ាកលម្អិតក្រៅពីមន្ត្រីរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលទទួលបន្ទុកត្រួតពិនិត្យម៉ាកនោះទេ។ ខ. មន្ត្រីជំនាញច្បាប់កម្មសិទ្ធិបញ្ញាដែលធ្លាប់បង្រៀនជំនាញកម្មសិទ្ធិបញ្ញាដល់បេក្ខជនត្រៀមប្រឡង ហើយដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម។ ក្នុងករណីនេះ លក្ខខណ្ឌថេរវេលានៃការងាររបស់មន្ត្រីជំនាញមិនមែនជាបញ្ហាដែរត្រូវពិចារណាឡើយ អ្វីដែរជាបញ្ហាប្រឈមរបស់មន្ត្រីជំនាញគឺលក្ខខណ្ឌនៃអតីតភាពបង្រៀនជំនាញកម្មសិទ្ធិបញ្ញាដល់បេក្ខជនក្នុងវគ្គត្រៀមប្រឡងទេតើ។ ជារួមបុគ្គលទាំងពីរប្រភេទខាងលើដែលបានបំពេញលក្ខខណ្ឌតម្រូវគ្រប់គ្រាន់ហើយ នឹងត្រូវចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ជាភ្នាក់ងារម៉ាក ដោយមិនបាច់ចូលរួមក្នុងការប្រឡង និងត្រូវបានចាត់ទុកថាប្រឡងជាប់ជាស្ថាពរ។ សរុបមក ការបង្កើតឲ្យមាននីតិវិធីក្នុងការទទួលបានលក្ខខណ្ឌគុណវុឌ្ឍិដោយស្វ័យប្រវត្តិ គឺដើម្បីជាការបង្ហាញពីលើទឹកចិត្តចំពោះមន្ត្រីរាជការដែលមានគុណសម្បត្តិគ្រប់គ្រាន់គួបផ្សំនឹងបច្ចេកទេសជំនាញក្នុងវិស័យម៉ាក។

[២៥] សូមមើលនៅឧបសម្ព័ន្ធ៦។

[២៦] សូមមើលនៅឧបសម្ព័ន្ធ៦។

មួយវិញទៀតសញ្ញាណនៃការទទួលបានមុខងារដោយស្វ័យប្រវត្តដូចភ្នាក់ងារម៉ាក យើងក៏ឃើញមានដែរនៅក្នុងវិជ្ជាជីវៈសារការីកម្ពុជា។ នៅឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៥០៥ អនក្រ/តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ សម្រេចតែងតាំងលោក **ប៉ែន សុនសម័យ**[២៧] ដែលជាសមាជិកមេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នូវមុខងារបន្ថែមជា **មេធាវីសារការី** ។ តាមរយៈអនុក្រឹត្យយើងអាចដឹងបានថា មូលហេតុដែលនាំឲ្យមានការតែងតាំងមេធាវីសារការី ពីព្រោះដោយឈរលើភាពចាំបាច់នៃតម្រូវការមុខងារសារការី ក្នុងប្រតិបត្តិការនានាលើវិស័យអចលនវត្ថុ និងក៏ដូចជាវិស័យដែលពាក់ព័ន្ធ ដែលតម្រូវឲ្យមានការចុះបញ្ជី ដើម្បីឲ្យមានការផ្ទេរកម្មសិទ្ធិ នោះមានសុពលភាព ហើយដោយកាលនោះពុំទាន់មានសារការីគ្រប់គ្រាន់នៅក្នុងប្រតិបត្តិការនោះផង ទើបរាជរដ្ឋាភិបាលសម្រេចតែងតាំងសារការីមេធាវី។ មួយវិញទៀតយើងអាចយល់បានថាមេធាវីគឺ ជាបុគ្គលដែលប្រកបដោយចំណេះដឹង និងជំនាញពាក់ព័ន្ធលើវិស័យច្បាប់នានាផង និងជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌មេធាវី។ បន្ថែមលើពីនេះវត្តមានមេធាវី នៅក្នុងវិស័យយុត្តិធម៌បានចូលរួមចំនែកយ៉ាងសំខាន់ក្នុងការជុំរុញប្រសិទ្ធភាពយុត្តិធម៌នៅក្នុងសង្គម។

សរុបមក ការទទួលបានការតែងតាំងមុខងារដោយស្វ័យប្រវត្តិគឺគ្រាន់តែជាមធ្យោបាយមួយសម្រាប់ ដោះស្រាយបញ្ហាប្រឈមចំពោះមុខនៃកង្វះខាតធនធានមនុស្សក្នុងដំណើរការអភិវឌ្ឍន៍ជាតិ និង ជាការលើកទឹកចិត្តចំពោះមន្ត្រីរាជការដែលខិតខំប្រឹងប្រែងអនុវត្តន៍ការងាររបស់ខ្លួន។

### ២.១.២ មូលហេតុនៃការបាត់បង់គុណវុឌ្ឍិជាភ្នាក់ងារម៉ាក

ការទទួលបានលក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាក ជាលក្ខខណ្ឌគ្រឹះដែលច្បាប់ម៉ាកតម្រូវសម្រាប់បុគ្គលដែលអនុវត្តន៍យន្តការតំណាងសិទ្ធិស្របច្បាប់របស់ម្ចាស់ម៉ាក។ ដោយឡែកថេរវេលានៃការអនុវត្តតួនាទីរបស់ភ្នាក់ងារម៉ាក គឺមិនមានថេរវេលាកំណត់នោះទេ[២៨]។ ទន្ទឹមនឹងការទទួលបានគុណវុឌ្ឍិជាភ្នាក់ងារម៉ាកហើយ ក៏មានដែរមូលហេតុដែលនាំឲ្យបាត់បង់ទៅវិញនូវគុណវុឌ្ឍិជាភ្នាក់ងារម៉ាក។ មូលហេតុនៃការកំណត់នូវលក្ខខណ្ឌបាត់បង់គុណវុឌ្ឍិ គឺដើម្បីពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារម៉ាក ឲ្យកាន់តែមានភាពច្បាស់លាស់នឹងប្រាកដប្រជា។ បើមិនដូចនេះទេ ដោយសំអាងលើរយៈពេលមិនកំណត់នៃការទទួលស្គាល់ និងដោយគ្មានការចែងអំពីលក្ខខណ្ឌបាត់បង់គុណវុឌ្ឍិនោះនឹងនាំឲ្យភ្នាក់ងារម៉ាកអនុវត្តតួនាទីដោយគ្មានខ្លាចក្រែងអ្វីឡើយ។

តើលក្ខខណ្ឌគុណវុឌ្ឍិជាភ្នាក់ងារម៉ាកត្រូវបាត់បង់ដោយមូលហេតុអ្វីខ្លះ?

[២៧] អនុក្រឹត្យស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, លេខ៥០៥ អនក្រ/តត, ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ សូមមើលនៅក្នុងឧប្បសម្ព័ន្ធ១។

[២៨] ប្រកាសស្តីពីភ្នាក់ងារម៉ាក, ប្រការ២៧។

### ២.១.២.១. ដោយឆន្ទៈផ្ទាល់ខ្លួន

លក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ភ្នាក់ងារម៉ាកនឹងត្រូវបានទៅវិញ ក្នុងករណីដែរភ្នាក់ងារនោះបានដាក់ពាក្យស្នើសុំបញ្ចប់ការទទួលស្គាល់ដោយខ្លួនឯងទៅនាយកដ្ឋានកម្មសិទ្ធិ។ ចំនុចដែលសំខាន់គឺពាក្យស្នើសុំត្រូវធ្វើឡើងជាលាយលក្ខអក្សរ និងស្តែងចេញពីទឹកចិត្តផ្ទាល់របស់សាមីខ្លួន ដោយពុំទាមទារឲ្យមានការបញ្ជាក់ហេតុផលអ្វីមួយឡើយ។ ក្នុងករណីនេះ ប្រសិនបើការស្នើសុំនោះធ្វើឡើងដោយមានការបង្ខិតបង្ខំ ហើយមានភស្តុតាងមកបញ្ជាក់ផងនោះ គួរតែពិចារណាផ្តល់នូវការទទួលស្គាល់លក្ខណៈសម្បត្តិគ្រប់គ្រាន់ជាភ្នាក់ងារម៉ាកវិញ។ ព្រោះថាករណីនេះពុំមានចែងក្នុងច្បាប់ ឬបទដ្ឋានពាក់ព័ន្ធនឹងម៉ាកនោះទេ។ តែយើងក៏អាចពិចារណាទៅលើគោលការណ៍នៃទំនាក់ទំនងរវាងហេតុ និងផលដែរ។ ចំណុចមួយទៀតដែលស្តែងឡើងតាមរយៈឆន្ទៈផ្ទាល់របស់ភ្នាក់ងារម៉ាក ហើយដែលជាហេតុធ្វើឲ្យបាត់បង់លក្ខណៈសម្បត្តិគ្រប់គ្រាន់ជាភ្នាក់ងារម៉ាកនោះគឺ ការមិនបានបង់ប្រាក់កម្រៃសមាជិកភាពប្រចាំឆ្នាំ។ ត្រង់ចំនុចនេះយើងឃើញថា ការបង់ប្រាក់កម្រៃសមាជិកភាពប្រចាំឆ្នាំ គឺជាយុទ្ធវិធីរដ្ឋក្នុងការប្រមូលពន្ធលើវិស័យពាក់ព័ន្ធនឹងម៉ាក ដើម្បីទ្រទ្រង់សេដ្ឋកិច្ចជាតិ និងក៏បានចងជាកាតព្វកិច្ចដាច់ខាតចំពោះភ្នាក់ងារម៉ាកណាដែរពុំបានអនុវត្តកាតព្វកិច្ច។

### ២.១.២.២. ដោយកំហុសធ្ងន់ធ្ងរ

សកម្មភាពប្រតិបត្តិរបស់ភ្នាក់ងារម៉ាក ដែលបង្កើតជាកំហុសធ្ងន់ធ្ងរនឹងឈានដល់ការត្រូវបាត់បង់លក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមច្បាប់។ ចំពោះកំហុសធ្ងន់ធ្ងរដែលឈានដល់ការបាត់បង់លក្ខខណ្ឌគុណវុឌ្ឍិនោះមានជាអាទិ៍៖ ក. ប្រើប្រាស់មធ្យោបាយក្លែងបន្លំណាមួយ ក្នុងគោលបំណងដើម្បីទទួលបានការទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។ ជាការកត់សម្គាល់ មធ្យោបាយក្លែងបន្លំ អាចស្តែងឡើងតាមគ្រប់រូបភាព តែយើងអាចពិចារណាលើលក្ខខណ្ឌនៃអំពើក្លែងបន្លំនោះបានគឺ ជាស្ថានភាពដែរផ្ទុយពីការពិត ហើយការពិតនេះហើយជាភស្តុតាងដែរអាចបញ្ជាក់តតាំងបាន។ ខ.បានប្រព្រឹត្តផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ។ គ. ភ្នាក់ងារម៉ាកបានធ្វើឲ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់អ្នកដាក់ពាក្យសុំចុះបញ្ជីម៉ាក ឬអ្នកដែលមានសិទ្ធិលើម៉ាក។

### ២.១.២.៣. ដោយហេតុផ្សេងៗ

ទន្ទឹមនឹងមានមូលហេតុដូចបានរៀបរាប់ខាងលើ ក៏នៅមានផងដែរនូវមូលហេតុមួយចំនួនទៀតដែលធ្វើឲ្យបាត់បង់លក្ខខណ្ឌគុណវុឌ្ឍិរបស់ភ្នាក់ងារម៉ាក ហើយដែលមូលហេតុទាំងនោះមានដូចជា៖ ក. ភ្នាក់ងារម៉ាកលែងមាននិវេសនដ្ឋាន និងទីតាំងប្រកបអាជីវកម្ម ឬការងារ នៅក្នុងព្រះរាជាណា

ចក្រកម្ពុជា។ ខ. ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក បាត់បង់សមត្ថភាព ឬទទួលមរណភាព។ គ. ចំពោះនីតិបុគ្គល លែងមានរូបវន្តបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឈរឈ្មោះឲ្យ។

## ២.២.សមត្ថកិច្ចភ្នាក់ងារម៉ាក

អនុលោមតាមច្បាប់ម៉ាក និងប្រកាសស្តីពីភ្នាក់ងារម៉ាក បើកលទ្ធភាពឲ្យយើងអាចសិក្សាស្វែងយល់បានអំពីសមត្ថកិច្ចរបស់ភ្នាក់ងាម៉ាក។ នៅទីនេះយើងនឹងធ្វើការបែងចែកសមត្ថកិច្ចរបស់ភ្នាក់ងារម៉ាកជាពីរទិដ្ឋភាពធំៗ ដោយទិដ្ឋភាពទីមួយ យើងនឹងសិក្សាអំពីភ្នាក់ងារម៉ាកជាតំណាងម៉ាករបស់ម្ចាស់ម៉ាក (២.២.១) ដោយឡែកទិដ្ឋភាពទីពីរនឹងនិយាយអំពីសមត្ថកិច្ចក្នុងការធ្វើអាជីវកម្មម៉ាក (២.២.១)។

### ២.២.១ ភ្នាក់ងារម៉ាកជាភ្នាក់ងារតំណាងម៉ាករបស់ម្ចាស់ម៉ាក

ទស្សនទាននៃច្បាប់ម៉ាក ក្នុងការបង្កើតយន្តការតំណាងស្របច្បាប់នៃម្ចាស់ម៉ាកគឺ ដើម្បីផ្តល់សមត្ថកិច្ចចម្បងដល់ភ្នាក់ងារម៉ាក។ តាមរយៈយន្តការតំណាង បានផ្តល់លទ្ធភាពដល់ភ្នាក់ងារម៉ាកក្នុងការអនុវត្តកិច្ចការតំណាងឲ្យម្ចាស់ម៉ាកផ្ទាល់ក្នុងដំណើរការស្នើសុំចុះបញ្ជីម៉ាក(២.២.១.១) និងភ្នាក់ម៉ាកនៅក្នុងនីតិវិធីដោះស្រាយវិវាទ(២.២.១.២)។

#### ២.២.១.១. ភ្នាក់ងារម៉ាកនៅក្នុងនីតិវិធីចុះបញ្ជីម៉ាក

ការចុះបញ្ជីម៉ាក គឺជាយន្តការតម្រូវតែមួយគត់ក្នុងការការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់ម៉ាក ពីការរំលោភបំពានរបស់តតិយជន។ ពិតណាស់ក្នុងដំណើរការស្នើសុំចុះបញ្ជី ភ្នាក់ងារម៉ាកមានតួនាទីចម្បងៗបីយ៉ាងដូចជាៈ

**តួនាទីមុនការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក**មានដូចជាៈ ភ្នាក់ងារម៉ាកត្រូវ សិក្សាវាយតម្លៃចំពោះម៉ាកស្នើសុំ អំពីលទ្ធភាពដែលអាចចុះបញ្ជីបាន នេះគឺជាជំហានចាប់ផ្តើមដំបូងដែរភ្នាក់ងារម៉ាកត្រូវអនុវត្តកិច្ចការតំណាងរបស់ខ្លួន។ ចំពោះការសិក្សាវាយតម្លៃលើម៉ាក ផ្តើមចេញពីការប្រមូលទិន្នន័យពាក់ព័ន្ធនឹងម៉ាកស្នើសុំតាមរយៈការធ្វើMark search[២៥] , វាយតម្លៃលើចំនុចចខ្លាំង និងចំណុចខ្សោយនៃម៉ាកស្នើសុំទាក់ទងនឹងលក្ខណៈដូចឬស្រដៀងនៃម៉ាកដ៏ទៃ និងភាពញែកដាច់ពីម៉ាកដទៃ និងផ្តល់នូវរបាយការណ៍

[២៥] Mark search អាចធ្វើឡើងបានតាមពីររបៀប ដោយស្នើសុំទៅមន្ត្រីកាន់កាប់បញ្ជីឲ្យធ្វើកិច្ចការនេះ និងដោយភ្នាក់ងារម៉ាកផ្ទាល់ តាមរយៈការចូលទៅស្វែងរកក្នុងប្រព័ន្ធទន្នន័យផ្លូវការរបស់នាយកដ្ឋានៈ www.cambodiaip.gov.kh/SearchMark.aspx

ក៏ដូចជាអនុសាសន៍ជូនម្ចាស់ម៉ាកជុំវិញលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន ដើម្បីឈានដល់ការសម្រេចចិត្តដាក់ពាក្យស្នើរសុំ។ ត្រង់ចំនុចនេះកិច្ចការដែលសំខានរបស់ភ្នាក់ងារម៉ាកគឺ បង្ហាញនូវភាពជឿជាក់ និងច្បាស់លាស់អំពីលទ្ធភាពដែលអាចចុះបញ្ជីបានស្របតាមច្បាប់ជូនដល់ម្ចាស់ម៉ាកពិចារណា។

**តួនាទីក្នុងពេលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក** រួមមាន៖ ភ្នាក់ងារម៉ាកត្រូវ រៀបចំ និងបំពេញនូវរាល់ឯកសារស្នើសុំ ដែលពាក់ព័ន្ធទាំងឡាយដាក់ជូននាយកដ្ឋានកម្មសិទ្ធិបញ្ញាពិនិត្យ។ ត្រង់ចំនុចនេះភ្នាក់ងារម៉ាកគឺត្រូវបង់កម្រៃ[៣០]ដាក់ពាក្យស្នើសុំចុះបញ្ជីចំនួន៣០ ០០០៛ បើមិនបានបង់ទេ នោះមានន័យថាពាក្យស្នើសុំនឹងត្រូវចាត់ទុកថាមិនបានដាក់មក។ បន្ទាប់មកតាមដានពីដំណើរការត្រួតពិនិត្យម៉ាករបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងករណីមានការស្នើសុំឲ្យមកបំភ្លឺនូវចំនុចណាមួយ ភ្នាក់ងារម៉ាកចាំបាច់ត្រូវតែចូលរួមជាបន្ទាន់ដើម្បីកុំឲ្យយឺតដល់នីតិវិធីពិនិត្យម៉ាក។ បន្ទាប់មកទៀត ក្នុងករណីមានវិវាទម៉ាកកើតឡើង ភ្នាក់ងារម៉ាកត្រូវ ដាក់ភស្តុតាំងគាំទ្រ និងភស្តុតាងតាងប្រឆាំងទៅវិញក្នុងករណីមានបណ្តឹងជំទាស់លើការចុះបញ្ជីម៉ាក។ ម៉្យាងវិញទៀតភ្នាក់ងារម៉ាក ក៏អាចស្នើសុំសវនាការ[៣១] ពីមន្ត្រីកាន់កាប់បញ្ជីក្នុងករណីជម្លោះមិនអាចឈានដល់ការបញ្ចប់។ មួយវិញទៀតក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីបដិសេធមិនចុះបញ្ជីជូន ភ្នាក់ងារម៉ាកត្រូវដាក់នូវមធ្យោបាយតប ដើម្បីជម្នះការបដិសេធមិនចុះបញ្ជីពីមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា។ ដោយឡែកមធ្យោបាយតប អាចធ្វើឡើងក្រោមទម្រង់ជាភស្តុតាងតាមគ្រប់បែប ឲ្យតែយល់ឃើញថាមានប្រយោជន៍ និងជាចុងក្រោយបន្ទាប់ពីទទួលបានលិខិតពីនាយកដ្ឋានតម្រូវឲ្យបង់ប្រាក់ ភ្នាក់ងារម៉ាកត្រូវបំពេញកាតព្វកិច្ចបង់ប្រាក់ចុះបញ្ជីម៉ាកនិងប្រកាសផ្សាយក្នុងប្រតិបត្តិអេឡិចត្រូនិក[៣២]ឲ្យទាន់ពេលកំណត់។

**តួនាទីក្រោយពេលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក** រួមមាន៖ ភ្នាក់ងារម៉ាកត្រូវតាមដាននូវព័ត៌មានទាក់ទងនឹងម៉ាកដែរបានប្រកាសផ្សាយក្នុង ប្រតិបត្តិផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៅរៀងរាល់មួយសប្តាហ៍ម្តង។ ការតាមដានគឺ ដើម្បីបង្ការក្រែងលោមានម៉ាក ដែរមានលក្ខណៈដូច ឬប្រហាក់ប្រហែលនឹងម៉ាករបស់ខ្លួនដែរបានចុះបញ្ជីរួច។ បន្ទាប់មក ក្នុងកំឡុងឆ្នាំទី៥បន្ទាប់ពីបានចុះបញ្ជីរួច ភ្នាក់ងារម៉ាកត្រូវដាក់ពាក្យប្រកាសអំពីការប្រើឬមិនប្រើម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងភ្នាក់ងារម៉ាកត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសារជាថ្មីបន្ទាប់ពីជិតផុតរយៈពេលការពារ(១០ឆ្នាំ)នៃម៉ាក។

[៣០] ប្រកាសរួមស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, លេខ១៦៤៣ សហវ.ប្រក,ដាក់អោយអនុវត្តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤, I.៣, ទំព័រទី៧(ពីពេលនេះតទៅហៅថា ប្រកាសរួមកម្រងសេវាសាធារណៈ)។

[៣១] ពាក្យសវនាការនៅក្នុងច្បាប់ម៉ាក មិនមានអត្ថន័យដូចសវនាការរបស់ស្ថាប័នតុលាការឡើយ។ វាគឺជានីតិវិធីដោះស្រាយវិវាទរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាតែប៉ុណ្ណោះ។

[៣២] ប្រកាសរួមកម្រងសេវាសាធារណៈ, I.៣, ទំព័រទី៧ សូមមើលនៅក្នុងឧប្បសម្ព័ន្ធ៣ ។

**២.២.១.២. ភ្នាក់ងារម៉ាកនៅក្នុងនីតិវិធីដោះស្រាយវិវាទម៉ាក**

វិវាទចំពោះម៉ាកភាគច្រើនតែងកើតមានជាប្រចាំចំពោះម៉ាកល្បី។ ព្រោះថាម៉ាកល្បី មានកេរ្តិ៍ឈ្មោះស្រាប់ មានអតិថិជនស្រាប់ មានទីផ្សារស្រាប់... ជាហេតុធ្វើឲ្យមានការកេងចំនេញផលប្រយោជន៍ពីម៉ាកល្បីតាមគ្រប់រូបភាព។ នេះមិនមែនមានន័យថា ម៉ាកមិនល្បីនឹងមិនមានវិវាទនោះទេ គ្រាន់តែមានករណីតិចតួចតែប៉ុណ្ណោះ។ ដោយហេតុនេះហើយបានជាភ្នាក់ងារម៉ាក ចូលរួមយ៉ាងសកម្មក្នុងដំណោះស្រាយវិវាទ ដើម្បីបុព្វហេតុការពារផលប្រយោជន៍ម្ចាស់ម៉ាក ដែលខ្លួនតំណាងសិទ្ធិ។ តួនាទីរបស់ភ្នាក់ងារម៉ាកត្រូវបានស្តែងឡើងតាមរយៈដំណោះស្រាយនៃវិវាទ មានដូចជាៈ

ក.ដាក់ពាក្យប្តឹងជំទាស់ទៅនឹងម៉ាកដែលកំពុងស្នើសុំចុះបញ្ជី ក្នុងករណីម៉ាកនោះមានលក្ខណៈដូច ឬប្រហាក់ប្រហែល ដែលអាចធ្វើឲ្យមានការភ័ន្តច្រឡំ។ ក្នុងករណីនេះភ្នាក់ងារម៉ាកត្រូវដាក់ភស្តុតាងបញ្ជាក់នឹងភស្តុតាងគាំទ្រតប ទៅមន្ត្រីត្រួតពិនិត្យម៉ាក។

ខ.ដាក់ពាក្យប្តឹងលុបម៉ាកចេញពីបញ្ជី ក្នុងករណីរកឃើញថា ម៉ាកនោះមានលក្ខខណ្ឌដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកទៅនឹងម៉ាកដែលបានចុះបញ្ជីរួច។ ដោយចំពោះករណីនេះ ភ្នាក់ងារម៉ាកត្រូវដាក់ភស្តុតាងបញ្ជាក់នឹងភស្តុតាងគាំទ្រតប ទៅកាន់មន្ត្រីដោះស្រាយវិវាទនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

គ.រៀបចំលិខិតជូនដំណឹងផ្សេងៗអាស្រ័យតាមករណីមួយៗ ទៅបុគ្គលដែលកំពុងរំលោភបំពាន ឬក្លែងម៉ាក ឲ្យបញ្ឈប់ជាបន្ទាន់នូវអំពើល្មើស។ ក្នុងករណីនេះភ្នាក់ងារម៉ាកត្រូវរាយការណ៍ និងសុំយោបល់ពីម្ចាស់ម៉ាកដែលខ្លួនតំណាង ដើម្បីសម្រេចចិត្ត ព្រោះថាទង្វើរំលោភបំពាននោះវាប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងប្រយោជន៍ជាខ្លាំង។

ឃ. ដាក់ពាក្យបណ្តឹងទៅប៉ូលីសសេដ្ឋកិច្ច ឬព្រះរាជអាជ្ញា ដើម្បីចាប់ និងរឹបអូសនូវទំនិញក្លែងបន្លំម៉ាក និងកសាងសំណុំរឿងទៅតុលាការ។ ក្នុងពេលជាមួយគ្នានេះដែរវត្តមានរបស់ភ្នាក់ងារម៉ាកនឹងម្ចាស់ម៉ាកផ្ទាល់គឺសំខាន់ក្នុងនីតិវិធីតុលាការណាស់ ព្រោះវាពាក់ព័ន្ធនឹងផលប្រយោជន៍របស់ម្ចាស់ម៉ាកជាខ្លាំង។

ង. ដាក់ពាក្យបណ្តឹងទៅរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ឲ្យឃូរទុកនូវទំនិញណាដែលសង្ស័យថា មានម៉ាកក្លែងក្លាយកំពុងចរាចរណ៍នៅតាមព្រំដែន។

ច.តួនាទីដែរសំខាន់មួយទៀតគឺ សម្រុះសម្រួលបញ្ចប់ជម្លោះរវាងម្ចាស់ម៉ាក និងបុគ្គលដែលរំលោភបំពាន។

សរុបមកការអនុវត្តតួនាទីរបស់ភ្នាក់ងារម៉ាកពិតជាមានភាពចាំបាច់ និងមិនអាចខ្វះបានឡើយ ក្នុងដំណោះស្រាយនៃវិវាទម៉ាក។

### ២.២.២ ភ្នាក់ងារម៉ាកជាជំនួយការរបស់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្មម៉ាក

ដូចបានបញ្ជាក់នៅខាងលើរួចមកហើយ មានតែម្ចាស់ម៉ាកមួយប៉ុណ្ណោះដែលមានសិទ្ធិផ្តាច់មុខលើម៉ាក។ តាមរយៈសិទ្ធិផ្តាច់មុខនេះហើយ ដែលអនុញ្ញាតឲ្យម្ចាស់ម៉ាក អាចចាត់ចែងបានដោយសេរីនូវសិទ្ធិដែលខ្លួនមាន ក្នុងនោះសិទ្ធិធ្វើអាជីវកម្មក៏ជាផ្នែកមួយនៃសិទ្ធិផ្តាច់មុខផងដែរ។ ដោយឡែកភ្នាក់ងារម៉ាកបានចូលរួមយ៉ាងសំខាន់ក្នុងប្រតិបត្តិការអាជីវកម្មនេះ ក្នុងឋានៈតំណាងឲ្យម្ចាស់ម៉ាក ដើម្បី ការពារប្រយោជន៍ដល់ម្ចាស់ម៉ាក និងជាពិសេសរៀបចំឯកសារដែលពាក់ព័ន្ធនៃប្រតិបត្តិការអាជីវកម្ម ធ្វើការចុះបញ្ជី និងកក់ត្រាជាមួយមន្ត្រីកាន់កាប់បញ្ជី ដើម្បីបំពេញលក្ខខណ្ឌតតាំងជាមួយតតីយជន។ សូមបញ្ជាក់ផងដែរថា សិទ្ធិក្នុងការធ្វើអាជីវកម្មរបស់ម្ចាស់ ឬហៅម្យ៉ាងទៀតថា សិទ្ធិបេតិកភណ្ឌរបស់ម្ចាស់ម៉ាក គឺសំដៅលើការធ្វើអាជីវកម្មតាមគ្រប់រូបភាព រួមទាំងសិទ្ធិក្នុងការផលិតឡើងវិញនូវម៉ាករបស់ខ្លួនលើទំនិញ ឬសេវាស្របតាមប្រភេទនៃទំនិញ ឬសេវាដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី។ លើសពីនេះទៀត ដោយហេតុម៉ាកជាទ្រព្យអរូបិយ បើកសិទ្ធិឲ្យម្ចាស់ម៉ាកអាចយកទៅដាក់បញ្ចាំ ដើម្បីទទួលបាននូវដើមទុនក្នុងការពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ពាណិជ្ជកម្ម រួមទាំងអាចធ្វើជាមូលនិធិពាណិជ្ជកម្មសម្រាប់សហគ្រាសរបស់ខ្លួនផងដែរ។ ចំនុចសំខាន់នៃប្រតិបត្តិការខាងលើគឺតម្រូវឲ្យ ភ្នាក់ងារម៉ាកដែរជាតំណាងរបស់ម្ចាស់ម៉ាក ត្រូវចុះបញ្ជី និងកក់ត្រាជាមួយមន្ត្រីកាន់កាប់បញ្ជី ដើម្បីជាលក្ខខណ្ឌតតាំងជាមួយតតិយជន[៣៣]។ ដោយឡែកការខកខានមិនបានចុះបញ្ជីនូវប្រតិបត្តិការផ្ទេរ ឬបញ្ចាំម៉ាក ពីម្ចាស់ដើមម៉ាកទៅតតិយជនពុំធ្វើឲ្យកិច្ចសន្យានៃប្រតិបត្តិការនីមួយៗបាត់បង់សុពលភាពឡើយ ប៉ុន្តែបានធ្វើឲ្យបាត់លទ្ធភាពតតាំងជាមួយតតិយជន។

#### ២.២.២.១. ភ្នាក់ងារម៉ាកនៅក្នុងប្រតិបត្តិការនៃកិច្ចសន្យា

ការធ្វើអាជីវកម្មតាមរយៈកិច្ចសន្យារបស់ម្ចាស់ម៉ាកមានច្រើនប្រភេទ។ ក៏មិនខុសគ្នាប៉ុន្មានដែរ តួនាទីរបស់ភ្នាក់ងារម៉ាកដែលតំណាងឲ្យម្ចាស់ម៉ាកក្នុងប្រតិបត្តិការនៃកិច្ចសន្យា មានភាពចាំបាច់ណាស់។ ក្នុងប្រតិបត្តិការនៃកិច្ចសន្យា ភ្នាក់ងារម៉ាកបានជួយសម្រួលដល់ម្ចាស់ម៉ាកក្នុងការសម្រេចចិត្ត ជាពិសេសគឺការពារផលប្រយោជន៍ម្ចាស់ម៉ាកស្របតាមការកំណត់របស់ច្បាប់។ បច្ចុប្បន្នការធ្វើអាជីវកម្មរបស់ម្ចាស់ម៉ាកតាមរយៈកិច្ចសន្យាគឺមានភាពរីកចំរើនគួរឲ្យកត់សម្គាល់ ក្នុងនោះទម្រង់នៃកិច្ចសន្យាពីរប្រភេទនឹងលើកយកមកបង្ហាញ ដើម្បីបញ្ជាក់អំពីតួនាទីភ្នាក់ងារម៉ាក។

- កិច្ចសន្យាអនុប្បទាន ស្តែងឡើងតាមរយៈកិច្ចសន្យាផ្ទេរសិទ្ធិកម្មសិទ្ធិអរូបិយ រវាងអនុប្បទានយី (ម្ចាស់សិទ្ធិ) និងអនុប្បទានិក(អ្នកទទួលសិទ្ធិ)។ នៅក្នុងច្បាប់ម៉ាក សញ្ញាណនៃកិច្ចសន្យាអនុប្បទានពុំបានកំណត់នោះទេ ប៉ុន្តែប្រសិនបើយើងមើលទៅលើប្រតិបត្តិការនៃកិច្ចសន្យា

[៣៣] ច្បាប់ម៉ាក, មាត្រា៤៨ ។

អនុប្បទាន វាពុំមានចរិតលក្ខណៈខុសពីកិច្ចសន្យាលក់ទិញឡើយ។ ការផ្ទេរម៉ាកអាចធ្វើឡើងក្នុងកំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក៏បានឬ ក្រោយពេលចុះបញ្ជីម៉ាករួចរាល់ក៏បាន ព្រោះថាក្នុងស្ថានភាពទាំងពីរនេះ ភ្នាក់ងារម៉ាកគ្រាន់តែដាក់ពាក្យស្នើសុំកែតម្រូវ ឬផ្លាស់ប្តូរម្ចាស់ម៉ាក ហើយត្រូវចុះបញ្ជី និងកត់ត្រាជាមួយមន្ត្រីកានកាប់បញ្ជីរួមទាំងប្រកាសផ្សាយជាការស្រេច។ ក្នុងករណីនេះ នឹងមានការផ្លាស់ប្តូរឋានៈនៃម្ចាស់សិទ្ធិលើម៉ាក ដោយក្នុងនោះតតិយជនដែលជាដៃគូរនៃកិច្ចសន្យាអនុប្បទាន នឹងត្រូវចូលមកជំនួសឋានៈជាម្ចាស់សិទ្ធិលើម៉ាកវិញ។ សូមបញ្ជាក់ផងដែរថា សម្រាប់ការជំនួសសិទ្ធិនេះ ច្បាប់ស្តីពីម៉ាកបានកំណត់នូវលក្ខខណ្ឌពិសេសនៃសុពលភាពរបស់កិច្ចគតិយុត្តមួយនេះផងដែរ។ ដោយឡែកចំពោះលក្ខខណ្ឌសុពលភាព ច្បាប់ម៉ាកបានចែងថា៖ ជាគោលការណ៍ កិច្ចសន្យាអាចធ្វើឡើងដោយការព្រមព្រៀមរវាងគូភាគី ហើយដែលអាចធ្វើឡើងក្នុងទម្រង់ជាលាយល័ក្ខអក្សរ ឬដោយផ្ទាល់មាត់។ យោងតាមមាត្រា៤៨ នៃច្បាប់ម៉ាក កិច្ចសន្យាអនុប្បទានតម្រូវឲ្យធ្វើឡើងជាលាយល័ក្ខអក្សរ។ ដើម្បីទទួលបានអានុភាពតតាំងជាមួយតតិយជន កិច្ចសន្យានេះត្រូវចុះបញ្ជីជាមួយមន្ត្រីកាន់កាប់បញ្ជី។ ចំពោះការខកខានពុំបានចុះបញ្ជីកិច្ចសន្យាអនុប្បទាននៃម៉ាកពុំបណ្តាលឲ្យកិច្ចសន្យានេះមោឃៈទេ ប៉ុន្តែវាពុំមានអានុភាពចំពោះតតិយជនឡើយ។ ម្យ៉ាងវិញទៀតកិច្ចសន្យាអនុប្បទាននេះនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យាអនុប្បទាននេះត្រូវបានធ្វើឡើងដោយមានវិការៈ[៣៤] ជាពិសេសចំពោះប្រភេទ ប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្របនៃទំនិញ ឬសេវាដែលម៉ាកនោះកំពុងប្រើប្រាស់ ឬបម្រុងនឹងប្រើប្រាស់[៣៥]។

- កិច្ចសន្យាអាជ្ញាប័ណ្ណ ជាកិច្ចសន្យាមួយដែលម្ចាស់ម៉ាក(អ្នកផ្តល់អាជ្ញាប័ណ្ណ)យល់ព្រមប្រគល់សិទ្ធិធ្វើអាជីវកម្មមួយផ្នែក ឬទាំងមូលនៃម៉ាកឲ្យទៅតតិយជន(អ្នកទទួលអាជ្ញាប័ណ្ណ) ដោយទទួលបានមកវិញនូវតម្លៃតបស្នង សមមូលទៅនឹងការអនុវត្តសិទ្ធិរបស់តតិយជនលើម៉ាក។ ក្នុងប្រតិបត្តិការនៃកិច្ចសន្យាអាជ្ញាប័ណ្ណនេះ ភ្នាក់ងារម៉ាកអនុវត្តន៍តួនាទី ដូចគ្នាទៅនឹងកិច្ចសន្យាអនុប្បទានផលដែរ។ យោងតាមមាត្រា៥២នៃច្បាប់ម៉ាក បានបញ្ញត្តតម្រូវឲ្យរាល់កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយលើម៉ាកដែលបានចុះបញ្ជីរួច ឬរាល់ពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យា ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដើម្បីធ្វើការចុះបញ្ជី និងចុះផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងកិច្ចសន្យាអាជ្ញាប័ណ្ណ ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យានោះ។ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជី ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់នូវខ្លឹមសារទាំងស្រុងនៃអាជ្ញាប័ណ្ណ ក៏ដូច

[៣៤] ក្រមរដ្ឋប្បវេណី,ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៨, មាត្រា៣៨៦ និងមាត្រា៣៨៧។

[៣៥] ច្បាប់ម៉ាក, មាត្រា៥១ ។

ជាពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យានោះ។ ការចុះបញ្ជី និងប្រកាសផ្សាយពីវត្តមាននៃកិច្ចសន្យាអាជ្ញាប័ណ្ណនេះ គឺនឹងផ្តល់អត្ថប្រយោជន៍សម្រាប់បង្កើតបាននូវអានុភាពតតាំងនឹងភាគីទីបីបាន[៣៦]។ ក្នុងន័យនេះ យើងក៏អាចបកស្រាយបានថា កិច្ចសន្យាអាជ្ញាប័ណ្ណក្នុងន័យនៃច្បាប់នេះ ក៏ត្រូវធ្វើឡើងក្រោមទម្រង់ លាយលក្ខណ៍អក្សរ និង ជាភាសាខ្មែរ ឬអង់គ្លេស ដែលដូចគ្នានឹងកិច្ចសន្យាអនុប្បទានផលដែរ។ លក្ខណៈពិសេសនៃកិច្ចសន្យាអាជ្ញាប័ណ្ណ ដែលខុសពីកិច្ចសន្យាអនុប្បទាន យើងអាចយល់បានតាមរយៈមាត្រា១៩នៃច្បាប់ម៉ាក គឺរាល់កិច្ចសន្យាអាជ្ញាប័ណ្ណ ក៏ដូចជាពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យាប្រភេទនេះ គឺត្រូវតែមានចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាពរបស់អ្នកប្រគល់អាជ្ញាប័ណ្ណ លើគុណភាពនៃទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញាប័ណ្ណដែលម៉ាកនោះ ត្រូវយកទៅប្រើជាមួយ។ ផ្ទុយទៅវិញប្រសិនបើ កិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាព ឬប្រសិនបើការត្រួតពិនិត្យគុណភាពនេះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាពទេ នោះកិច្ចសន្យាអាជ្ញាប័ណ្ណ ក៏នឹងត្រូវចាត់ទុកជាមិនបានការដែរ[៣៧]។

សរុបមក តួនាទីរបស់ភ្នាក់ងារម៉ាកនៅក្នុងប្រតិបត្តិការនៃកិច្ចសន្យា គឺមានសារសំខានចំពោះផលប្រយោជន៍របស់ម្ចាស់ម៉ាកដើម ក៏ដូចគ្នាចំពោះភាគីនៃកិច្ចសន្យា។ ព្រោះថាច្បាប់ម៉ាកបានចែងអំពីលក្ខណៈពិសេសនៅក្នុងសកម្មភាពនៃប្រតិបត្តិការអាជីវកម្មលើម៉ាក។ ចំពោះលក្ខណៈពិសេសនេះហើយ ដែលភ្នាក់ងារម៉ាកយល់ច្បាស់អំពីនីតិវិធី និងជាបុគ្គលតែម្នាក់គត់ដែលច្បាប់ម៉ាកទទួលស្គាល់សម្រាប់ការស្នើរសុំបំពេញលក្ខខណ្ឌពិសេសនេះបន្ទាប់ពីម្ចាស់ម៉ាក។

### ២.២.២.២. ភ្នាក់ងារម៉ាកនៅក្នុងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា

ម៉ាកគឺជាទ្រព្យសម្បត្តិអរូបិយ ដ៏មានតម្លៃមហាសាលរបស់ម្ចាស់ម៉ាក។ ស្របតាមអត្ថន័យនេះហើយ ម្ចាស់ម៉ាកអាចយកទ្រព្យអរូបិយរបស់ខ្លួននេះទៅធ្វើប្រតិបត្តិការគតិយុត្តនានា ដើម្បីពង្រីកទំហំអាជីវកម្ម បង្កើនលទ្ធភាពវិនិយោគថ្មីជាអាទិ៍។ ដោយឡែកចំពោះការវាយតម្លៃលើទ្រព្យកម្មសិទ្ធិបញ្ញា យោងតាមប្រកាសស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ប្រការ៣ បានចែងអំពីតួនាទីរបស់ភ្នាក់ងារម៉ាកក្នុងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា។ ប៉ុន្តែពុំបានចែងអំពីវិធាន ឬនីតិវិធីក្នុងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញានេះឡើយ។ ត្រង់ចំនុចនេះបញ្ជាក់ឲ្យឃើញពីអលទ្ធភាពរបស់ភ្នាក់ងារម៉ាកនៅកម្ពុជា ក្នុងការវាយតម្លៃលើទ្រព្យកម្មសិទ្ធិបញ្ញា ជាពិសេសម៉ាកតែម្តង។ ស្របតាមអត្ថន័យនេះដែរ បានធ្វើឲ្យលេចចេញនូវស្ថានភាពដ៏ជាក់ច្បាស់អំពី កម្រោយនៃច្បាប់ជាតិពាក់

---

[៣៦] ច្បាប់ម៉ាក, មាត្រា៥២ ។

[៣៧] កាន់ សុទ្ធប៉ូលីន, នីតិកម្មសិទ្ធិបញ្ញាៈសិទ្ធិអ្នកនិពន្ធ/ម៉ាក/ប្រកាសនីយបត្រតក្កកម្ម,(ភ្នំពេញៈ ១៦,២, ២០១៤),១៦០។

ព័ន្ធនឹងវិស័យម៉ាក, ការយល់ដឹងរបស់មន្ត្រីកាន់កាប់បញ្ជីនៅមានកម្រិត, អលទ្ធភាពរបស់ម្ចាស់ម៉ាកក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនលើម៉ាកឲ្យអស់លទ្ធភាព...។

ផ្ទុយទៅវិញនិន្នាការទាក់ទងនឹងការវាយតម្លៃលើទ្រព្យកម្មសិទ្ធិបញ្ញានៃម៉ាកល្បី ត្រូវបានអនុវត្តន៍ដោយផ្អែកលើកត្តាសត្យានុម័ត៣[៣៨]យ៉ាងគឺ ១. កត្តាមូលដ្ឋានតម្លៃដើមនៃការចំណាយលើម៉ាក(Cost Based Brand Valuation) មានន័យថា ការវាយតម្លៃដោយប្រើផលបូកនៃការចំណាយ ឬតម្លៃបុគ្គលនៃទ្រព្យសកម្ម និងបំណុល។ ការចំណាយត្រូវគិតតាំងពីរយៈពេលកកើតដំបូងនៃម៉ាក រហូតដល់ពេលវាយតម្លៃម៉ាក់ ទៅលើចំនុចចំបាច់មួយចំនួនដូចជា៖ ការចំណាយលើ ការរចនាម៉ូតម៉ាក, ការផ្សព្វផ្សាយពាណិជ្ជកម្មតាមគ្រប់រូបភាព, ការចំណាយក្នុងកម្មវិធីប្រម៉ូតសិន, ,ការចុះបញ្ជីម៉ាក និងសេវាភ្នាក់ងារម៉ាក, ការចំណាយដើម្បីទទួលបានអាជ្ញាប័ណ្ណ,...។ ២. កត្តាវាយតម្លៃលើម៉ាកដោយផ្អែកលើទីផ្សារ (Market-Based Brand Valuation) មានន័យថា ជាការធ្វើការប្រៀធៀបតម្លៃម៉ាកដែលប្រហាក់ប្រហែលគ្នាមួយ ឬច្រើននៅពេលដែលបានលក់ចេញ។ ការវាយតម្លៃម៉ាកដោយវិធីនេះស្មើនឹងតម្លៃប្រតិបត្តិការទីផ្សារ ការលក់ដេញថ្លៃលើម៉ាកដែលស្រដៀងគ្នា។ មូលហេតុនៃការប្រៀបធៀបមួយម៉ាកជទៃគឺ ជាយុទ្ធសាស្ត្រនៃការស្ទាបស្ទង់តម្លៃទីផ្សាររួម ឬទៅលើតម្លៃទីផ្សារភាគហ៊ុនអន្តរជាតិ។ ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ មុខឈានដល់ការសម្រេចតម្លៃលក់។ ៣. កត្តាវាយតម្លៃលើប្រាក់ចំណូល (Income Approach Brand Valuation) មានន័យថា គឺជាប្រមាណទុកនូវប្រាក់ចំណូលអនាគតរបស់ម៉ាក។ វិធីសាស្ត្រនេះធ្វើឡើងដោយផ្អែកទៅលើទិន្នន័យ នៃប្រាក់ចំណូលប្រចាំឆ្នាំ (ដែលបានមកពីការធ្វើអាជីវកម្មលើម៉ាក) កន្លងមកពីរបីឆ្នាំជាប់គ្នា យកមកធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃលើប្រាក់ចំណូលរបស់ម៉ាកក្នុងពេលអនាគត។ ជាការកត់សំគាល់ ការប្រើយន្តការទី៣ខាងលើនេះ ត្រឹមត្រូវគឺអាស្រ័យលើកេរ្តិ៍ឈ្មោះរបស់ម៉ាក។

ឧទាហរណ៍៖ ក្រុមហ៊ុនទស្សនាវដ្ដី Forbes[៣៩] បានចេញនូវរបាយការណ៍ចំណាត់ថ្នាក់នៃការវាយតម្លៃលើម៉ាកល្បីគតិជាប៊ីលានដុល្លា សម្រាប់ឆ្នាំ២០១៧ ។(សូមមើលនៅឧបសម្ព័ន្ធ ៤)

[៣៨] ដកស្រង់ពីគេហទំព័រ, www.thebalance.com/how-to-calculate-your-brand-s-value-2295186 (ថតចម្លងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧) ។

[៣៩] ដកស្រង់ពីគេហទំព័រ, www.forbes.com/powerful-brands/list/#tab:rank(ថតចម្លងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧)។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ ចងក្រង សរសេរអត្ថបទរបាយការណ៍ លើប្រធានបទ "ភ្នាក់ងារម៉ាកនៅកម្ពុជា" នេះឡើង យើងឃើញថា ភ្នាក់ងារម៉ាកគឺជាអ្នកតំណាងសិទ្ធិដោយស្របច្បាប់របស់ម្ចាស់ម៉ាក ហើយអនុវត្តន៍កិច្ចការនានាដើម្បីការពារប្រយោជន៍ម្ចាស់ម៉ាកជាម្បង។ ឬអាចនិយាយមួយបែបទៀតថាភ្នាក់ងារម៉ាក គឺជាកម្លាំងចលកររបស់ម្ចាស់ម៉ាកក្នុងការជំរុញរយៈពេលនៃនីតិវិធីចុះបញ្ជីឲ្យកាន់តែឆាប់រហ័ស ដើម្បីឆាប់ទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក។ ដូចយើងបានដឹងជាទូទៅហើយថា សិទ្ធិផ្តាច់មុខលើម៉ាកមួយគឺផ្តល់ឲ្យតែទៅលើម្ចាសម៉ាកម្នាក់តែប៉ុណ្ណោះ។ តាមរយៈសិទ្ធិផ្តាច់មុខនេះបានផ្តល់ឲ្យម្ចាស់ម៉ាក មានលទ្ធភាពក្នុងការចាត់ចែងបានដោយសេរីនូវសិទ្ធិរបស់ខ្លួនដែលមានលើម៉ាកជាអាទិ៍ៈ ម្ចាស់ម៉ាកអាចយកម៉ាកទៅធ្វើការដាក់ធានាដើម្បីសងបំណុល, ម្ចាស់ម៉ាកអាចលក់ម៉ាក ឬជួលម៉ាករបស់ខ្លួនឲ្យទៅតតិយជនដើម្បីទទួលបានកម្រៃតបវិញ, ឬម្ចាស់ម៉ាកអាចយកម៉ាកទៅធ្វើជាកម្មវត្ថុនៃប្រទានកម្មក៏បាន។ បន្ថែមលើសពីនេះសិទ្ធិផ្តាច់មុខ បានការពារម្ចាស់ម៉ាកប្រឆាំងទៅនឹងការរំលោភបំពានពីតតិយជនតាមគ្រប់មធ្យោបាយ។

ក្នុងការសិក្សាអំពីប្រវត្តិរបស់ភ្នាក់ងារម៉ាក បានបង្ហាញយើងឲ្យយល់ដឹងអំពីរបៀបនៃការកកើតភ្នាក់ងារម៉ាក ក្រោមបរិបទអវត្តមាននៃបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រង និងការប្រែប្រួលរបបនយោបាយគ្រប់គ្រងប្រទេស។ ស្ថានភាពនេះសបញ្ជាក់ឲ្យឃើញថា ការអនុវត្តកិច្ចការពារម៉ាកធ្វើឡើងក្រោមទម្រង់នៃឆន្ទៈប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងការទាមទាររបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក បានខិតខំរៀបចំតាក់តែងច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួនស្របតាមច្បាប់អន្តរជាតិ ដើម្បីបំពេញលក្ខខណ្ឌតម្រូវ។ ជាលទ្ធផល នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ កម្ពុជាបានចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ តាមរយៈការឈានជើងចូលជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនេះហើយ បានហុចឱកាសឲ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់នឹងទទួលបានការទុកចិត្ត អនុញ្ញាឲ្យកម្ពុជាបានចូលជាសមាជិកទី១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។ បន្ទាប់មកកម្ពុជានៅតែបន្តកិច្ចការពារលើវិស័យកម្មសិទ្ធិបញ្ញាបន្តទៀត ដោយសម្រេចបាននូវច្បាប់ និងបទដ្ឋានមួយចំនួនបន្ថែមទៀតទាក់ទងនឹងវិស័យម៉ាកក៏ដូចជាភ្នាក់ងារម៉ាកផងដែរ។ ជាលទ្ធផលភ្នាក់ងារម៉ាកកំពុងអនុវត្តកិច្ចការរបស់ខ្លួនបានយ៉ាងល្អប្រសើរដោយសហការគ្នាជាមន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញាក្នុងការពង្រឹងគុណភាព និងពង្រីកចំណេះដឹងថ្មីៗបន្ថែមទៀតតាមរយៈការបើឲ្យមានសិក្ខាសាលា[៩០]ផ្សេងៗទាក់ទងនឹងវិស័យម៉ាក ជូនដល់គ្រប់ភាគីដែលពាក់ព័ន្ធជាពិសេសគឺភ្នាក់ងារម៉ាកនេះតែម្តង។

[៩០] ជាក់ស្តែងក្រសួងពាណិជ្ជកម្មសហការជាមួយនឹងទីភ្នាក់ងារម៉ាកជប៉ុន បានបើសិក្ខាសាលាមួយស្តីពីកិច្ចការពារសមស្របនៃពាណិជ្ជសញ្ញា, ធ្វើឡើងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧។

ម៉្យាងវិញទៀតយើងឃើញថាតួនាទីរបស់ភ្នាក់ងារម៉ាក មានប្រសិទ្ធភាពជាខ្លាំងក្នុងនីតិវិធីចុះបញ្ជីម៉ាក , ការចូលរួមដោះស្រាយវិវាទនានាដែលកើតមាន, ជំរុញឲ្យមានការរីកចម្រើនដល់កំនើននៃការប្រមូលពន្ធរបស់រដ្ឋ, ជំរុញឲ្យមានការវិនិយោគកាន់តែច្រើនឡើង តាមយៈប្រសិទ្ធភាពនៃការអនុវត្តច្បាប់,...។

ទោះបីជាខ្ញុំបាទបានខិតខំធ្វើការស្រាវជ្រាវ បកស្រាយយ៉ាងយកចិត្តទុកដាក់ ដោយឈរលើមូលដ្ឋានច្បាប់ ក៏ដូចជា ឈរលើការអនុវត្តជាក់ស្តែងយ៉ាងណាក៏ដោយ ខ្ញុំបាទពិតជាជឿជាក់ថា រាល់កំហុស និងការខ្វះខាតប្រាកដជាកើតមានជាក់ជាពុំខាន នេះដោយហេតុម៉្យាងថា ប្រធានបទខាងលើនេះជា ប្រធានបទថ្មីដែលពីមុនមកពុំធ្លាប់មានអ្នកយកមកធ្វើការបកស្រាយនៅឡើយទេ។ យ៉ាងណាម៉ិញ ប្រធានបទរបាយការណ៍នេះ ជាប្រធានបទដ៏លំបាកមួយផងដែរ ព្រោះតាមរយៈអត្ថន័យនៃភ្នាក់ងារម៉ាក គឺពុំត្រូវបានឲ្យនិយមន័យជាក់ច្បាស់នៅក្នុងច្បាប់ ក៏ដូចជាប្រកាសនោះដែរ។ ហេតុនេះខ្ញុំបាទរំពឹង និងរង់ចាំការរិះគន់ពីសំណាក់ជនានុជនគ្រប់មជ្ឈដ្ឋាន ក្នុងការសិក្សាកែសម្រួលបន្តលើ ប្រធានបទនេះឲ្យកាន់តែល្អប្រសើរឆ្ពោះទៅរកភាពគ្មានចន្លោះខ្វះខាត ដើម្បីជាការបង្កើន និងជាកម្លាំងចលករជំរុញការរីកចម្រើននៃវិស័យកម្មសិទ្ធិបញ្ញានិយាយជារួម និងនិយាយដោយឡែកវិស័យម៉ាក និងភ្នាក់ងារម៉ាក ប្រព្រឹត្តទៅបានដោយសម្បូរបែបនៃឯកសារជាតិ និងប្រកបដោយភាពជាទីទាក់ចិត្តរបស់ប្រជាពលរដ្ឋទូទៅ។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីដំណើរការ នៃការសរសេរសារណាកន្លងមកឃើញថា មានឯកសារដែលទាក់ទងនឹងភ្នាក់ងារម៉ាកថ្មីៗមួយចំនួនបានដាក់ឲ្យទាញយកដោយសេរីពីគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាកម្ពុជា។ តែចំពោះឯកសារគតិយុត្តសំខាន់ៗមួយចំនួនធំ ដែលពាក់ព័ន្ធនឹងការចាប់ផ្តើមកសាងវិស័យកម្មសិទ្ធិបញ្ញាតាំងតាំងពីឆ្នាំ១៩៩១មកដល់ឆ្នាំ២០០៥ គឺពុំបានឃើញដាក់បញ្ចូលនៅក្នុងគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានោះទេ។ ម៉្យាងវិញទៀតថ្វីត្បិតតែក្នុងពេលបច្ចុប្បន្ន យើងមានច្បាប់ និងលិខិតបទដ្ឋានមួយចំនួនទាក់ទង់នឹងវិស័យកម្មសិទ្ធិបញ្ញា , ម៉ាក និងភ្នាក់ងារម៉ាកក៏ដោយ ក៏ស្ថានភាពចំពោះមុខក្នុងការអនុវត្ត យើងនៅខ្វះខាតច្បាប់ និងបទដ្ឋានគតិយុត្តបន្ថែមជាច្រើនទៀត។ ទើបអាចបំពេញតម្រូវការនៃការរីកចំរើនខាងវិស័យកម្មសិទ្ធិបញ្ញាបាន។ ដូចនេះដើម្បីឲ្យមានការរីកចំរើនបន្ថែមទៀត និងដើម្បីប្រសិទ្ធភាពការងារពាក់ព័ន្ធនឹងម៉ាក ខ្ញុំបាទសូមអនុញ្ញាតជូនជាអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

❖ រាជរដ្ឋាភិបាលគួរ៖

- ប្រមូលគ្រប់ផ្នែកដែរពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា រួមបញ្ចូលគ្នាជាស្ថាប័នគ្រប់គ្រងដោយឯករាជ្យតែមួយ។
- ដាក់ចេញគោលនយោបាយកម្មសិទ្ធិបញ្ញា ក្នុងគោលដៅជំរុញនឹងលើទឹកចិត្តដល់ប្រជាពលរដ្ឋស្វែងយល់ពីវិស័យនេះ និងបញ្ចូលជាមេរៀនកម្មសិទ្ធិបញ្ញាក្នុងកម្មវិធីសិក្សាតាំងពីបឋមសិក្សាឡើងទៅ។
- ធ្វើការផ្សព្វផ្សាយតាមរយ:វិទ្យុ, ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយសង្គម អំពីសារប្រយោជន៍នៃភ្នាក់ងារម៉ាក ក៏ដូចជាកម្មសិទ្ធិបញ្ញា។
- គួរបង្កើនលទ្ធភាពដល់ការគ្រប់គ្រងចំណូរពីវិស័យម៉ាកដោយអង្គភាពសាមីផ្ទាល់។
- ជំរុញសមត្ថភាព និងចម្រាញ់យកមន្រ្តីមានសមត្ថភាពខ្ពស់លើវិស័យកម្មសិទ្ធិបញ្ញា។
- ពង្រឹងដល់ការអនុវត្តច្បាប់ឲ្យខានតែបានលើវិស័យកម្មសិទ្ធិបញ្ញា។

❖ ក្រសួងពាណិជ្ជកម្មគួរ៖

- រៀបចំតាក់តែងឲ្យមានច្បាប់ស្តីពីភ្នាក់ងារម៉ាកដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ ដោយមានចែងលំអិតអំពីតួនាទី ភារកិច្ច សិទ្ធិ នីតិវិធីក្នុងការអនុវត្តតួនាទីនីមួយឲ្យបានច្បាស់លាស់ជាអាទិ៍ ដើម្បីបំពេញបន្ថែមលើប្រកាសដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។
- បន្តសហការជាមួយដៃគូរជាតិ និងអន្តរជាតិ ដើម្បីបើកវគ្គអប់រំ និងបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធ ជាពិសេសប្រជាជននៅតាមជនបទ។
- កំណត់អំពីរយ:ពេលនីមួយៗក្នុងនីតិវិធីចុះបញ្ជីម៉ាកឲ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីធានាបានអំពើពុករលួយ។

# ឯកសារយោង

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦
- រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ ១៩៨១
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នា១៩៩៣
- ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៨។
- ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២។
- ច្បាប់ស្ដីពី លក្ខន្តិកៈមេធាវី ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៩។
- អនុក្រឹត្យស្ដីពី ការផ្ដល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, លេខ៥០៥ អនក្រ/តត, ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១។
- អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ លេខ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦។
- ប្រកាសស្ដីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា លេខ ០៤៥ Moc/SM2011 ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។
- ប្រកាសរួមស្ដីពី ការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួម លេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម លេខ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤។

## ២. សៀវភៅជំនាញ

- សៀវភៅ នីតិកម្មសិទ្ធិបញ្ញា (សិទ្ធិអ្នកនិពន្ធ/ម៉ាក/ប្រកាសនីយបត្រតក្កកម្ម) របស់លោក **កាន់ សុទ្ធប៉ូលីន** ឆ្នាំ២០១៤(ពោងពុម្ព qb)។
- សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា របស់លោក **នី វិចិត្រ** ឆ្នាំ២០១៣។

### ៣.ឯកសារផ្សេងៗ

- ឯកសារបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាលភ្នាក់ងារម៉ាកជំនាន់ទី៣ ការអភិវឌ្ឍកម្មសិទ្ធិបញ្ញានៅកម្ពុជា របស់លោក Penn Sovicheat ឆ្នាំ២០១៦។
- ក្រសួងពាណិជ្ជកម្មសហការជាមួយនឹងទីភ្នាក់ងារម៉ាកជប៉ុន បានបើសិក្ខាសាលាមួយស្តីពីកិច្ចការពារសមស្របនៃពាណិជ្ជសញ្ញា, ធ្វើឡើងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧
- U.S. Trademark Law (u.s. Patent & Trademark office) December 28 2009
- Charter of The United Nations and Statute of The International Court of Justice San Francisco 1945
- Trademark Law of The People´s Republic of China March 1 198

### ៤. គេហទំព័រដែលពាក់ព័ន្ធ

- www.forbes.com/powerful-brands/list/#tab:rank
- www.thebalance.com/how-to-calculate-your-brand-s-value-2295186
- www.cambodiaip.gov.kh/SearchMark.aspx
- www.wipo.int/branddb/kh/en/
- www.cambodiaip.gov.kh/TemplateTwo.aspx?parentId=78&menuid=320&childMasterMenuId=320
- www.wto.org/english/thewto_e/acc_e/a1_cambodge_e.htm
- www.ukessays.com/essays/economics/asean-and-history-of-cambodias-membership-economics-essay.php
- www.wipo.int/members/en/details.jsp?country_id=90
- www.cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=39&childMasterMenuId=29
- www.uspto.gov/sites/default/files/trademarks/law/Trademark_Statutes.pdf

- www.wipo.int/wipolex/en/text.jsp?file_id=188401
- www.cncpi.fr/sta144-44-LA-CNCPI.htm
- www.wipo.int/wipolex/en/details.jsp?id=13198

# ឧបសម្ព័ន្ធ

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់សមត្ថកិច្ចបន្ថែមជាសារគារីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥
- យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

### មាត្រា ១

តែងតាំង លោក ម៉ែនសុន សម័យ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាមាន អត្តលេខ ៥៤ បន្ថែមលើមុខងារបច្ចុប្បន្នជា សារគារី ដែលហៅថា "មេធាវីសារគារី" ។
~~~~~

**មាត្រា ២.**

**មេធាវីសារការី**ជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ ។

**មាត្រា ៣.**

**មេធាវីសារការី**មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ, ចលនវត្ថុ និង អចលនវត្ថុ ជាអាទិមាន :

ក- ទទួល និង ធ្វើ ឬ ចារឹកបញ្ជាក់ និង ប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬ កិច្ចសន្យាទាំងឡាយ ដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ- ធ្វើការបញ្ជាក់លើកាលបរិច្ឆេទ, ទទួលតំកល់ទុកឯកសារ និងចេញអោយនូវសេចក្តីដើម ឬសេចក្តីចម្លង នៃលិខិត ឬ កិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ- កិច្ចការនេះត្រូវពិនិត្យ, អានឱ្យអស់សេចក្តី និង ចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប **មេធាវីសារការី** ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនាពេលនោះជាចុងក្រោយ ។

**មាត្រា ៤.**

**មេធាវីសារការី** ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០.០០០.០០០.០០ ( ប្រាំមួយរយលានរៀល) នៅធនាគារជាតិនៃកម្ពុជា សំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទិស្តិការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ និង ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ០៤ MOC / SM 2011

# ប្រកាស
## ស្តីពី
## ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០២៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ .បក ចុះថ្ងៃទី ១២ កក្កដា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
-បានឃើញប្រកាសលេខ ២១១ MOC/SM ២០០៧ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា របស់ក្រសួងពាណិជ្ជកម្ម
-បានឃើញប្រកាសលេខ ១០៥ MOC/SM ២០០៩ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី អំពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ
-យោងតាមសំណូមពរចាំបាច់នៃការងារ

## <u>ស ម្រេ ច</u>

### ប្រការ ១ : គោលដៅ

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ និងនីតិវិធីទទួលស្គាល់បុគ្គលធ្វើជាតំណាងស្របច្បាប់នៃម្ចាស់ម៉ាក់ ដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខៈ (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីមែលៈ moccab@moc.gov.kh

## ប្រការ ២ ៖ គោលបំណង

ប្រកាសនេះមានគោលបំណង ៖

១- គ្រប់គ្រង និងពង្រឹងសមត្ថភាពរបស់តំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដើម្បីសម្រួលដល់ការងារចុះបញ្ជី និង កិច្ចការដទៃទៀតដែលទាក់ទងនឹងម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឱ្យមានភាពរលូនប្រកបដោយប្រសិទ្ធភាព ។

២- ផ្តល់ភាពងាយស្រួលដល់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្ម និង ការការពារសិទ្ធិរបស់ខ្លួន តាមរយៈតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ។

## ប្រការ ៣ ៖ និយមន័យ និង វិសាលភាព

ម៉ាកសំដៅដល់ ម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ប្រកាសនេះគ្រប់ដណ្តប់ទៅលើការងារផ្សេងៗដែលទាក់ទងទៅនឹងម៉ាក ដូចជា ការចុះបញ្ជី ការធ្វើអាជីវកម្ម ការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា និងការអនុវត្តន៍សិទ្ធិរបស់ម្ចាស់ម៉ាកក្នុង និង ក្រៅប្រទេស ជាដើម ។

## ប្រការ ៤ ៖ ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក

១- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល តំណាងឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ដើម្បីបំពេញកិច្ចការចំពោះមុខនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។ ភ្នាក់ងារតំណាងស្របច្បាប់ នៃម្ចាស់ម៉ាក ត្រូវមានលក្ខណៈសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ហើយត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួង ពាណិជ្ជកម្ម ។

២- បរិមាណភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក មិនត្រូវបានកំណត់ចំនួនឡើយ ។ រូបវន្តបុគ្គលដែលបានប្រឡងជាប់ជាស្ថាពរ ត្រូវបានចាត់ទុកថាមានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ក្នុងការធ្វើជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ។

៣- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក អាចបង្ហាញខ្លួនក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា តែក្នុងករណី មិនផ្ទុយនឹងច្បាប់ និង បទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

៤- ផ្អែកតាមសំណើ រូបវន្តបុគ្គលណាមួយអាចនឹងត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក លុះត្រាតែបុគ្គលនោះ បំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ និង
- មាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង
- មានទីតាំងប្រកបអាជីវកម្ម ឬការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង
- ជាប់ជាស្ថាពរក្នុងការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឬត្រូវបានចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ដូចមានចែងក្នុងប្រការ ២៦ និង
- មិនផ្ទុយនឹងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

៥- ផ្អែកតាមសំណើ នីតិបុគ្គលអាចនឹងត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក លុះត្រាតែ ៖

- មានបុគ្គលិកជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកយ៉ាងតិចមួយនាក់ឈរឈ្មោះអោយ និង
- មាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

៦-រូបវន្តបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកម្នាក់ អាចឈរឈ្មោះអោយនីតិបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់តែមួយគត់ ។

## ប្រការ ៥ ៖ ការរៀបចំការប្រឡង

ក្នុងករណីមានចំនួនបេក្ខជនសមស្រប ការប្រឡងសមត្ថភាពសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក នឹងត្រូវរៀបចំធ្វើឡើង យ៉ាងតិចមួយដងក្នុងមួយឆ្នាំ ឬតាមការចាំបាច់ ។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងរៀបចំបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និង លេខាធិការដ្ឋានប្រឡង ។

## ប្រការ ៦ ៖ ក្រុមប្រឹក្សាប្រឡង

១- ក្រុមប្រឹក្សាប្រឡងមានតួនាទីជ្រើសរើសមន្ត្រីជំនាញ ដើម្បីបង្រៀនដល់បេក្ខជនត្រៀមប្រឡង និងរៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ។

២- ក្រុមប្រឹក្សាប្រឡង មានសមាសភាពចំនួន ០៧ រូប រួមមាន ÷

ក-ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម

ខ-ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងពាណិជ្ជកម្ម

គ-មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ចំនួន ០៣រូប និងមន្ត្រីនាយកដ្ឋានបុគ្គលិក នៃក្រសួងពាណិជ្ជកម្ម ចំនួន ០២រូប ដែលស្នើសុំតែងតាំងដោយប្រធាននាយកដ្ឋានសាមី ។

៣- ប្រធាន និងអនុប្រធានក្រុមប្រឹក្សាប្រឡង ត្រូវជ្រើសរើសចេញពីសមាជិករបស់ខ្លួន ។

៤-ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និងប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម អាចតែងតាំងមន្ត្រីមួយរូបតាមជម្រើសរបស់ខ្លួន ដើម្បីកាន់តំណែងជំនួសក្នុងក្រុមប្រឹក្សាប្រឡង សម្រាប់រយៈពេលណាមួយ ។

## ប្រការ ៧ ៖ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រឡង

១- រៀបចំសមាសភាពគណៈកម្មការប្រឡង និង លេខាធិការដ្ឋានប្រឡង ដើម្បីសុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

២- ជ្រើសរើសគ្រូបង្រៀនជំនាញកម្មសិទ្ធិបញ្ញាក្នុងចំណោមមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានសមត្ថភាព និងគរុកោសល្យ ដើម្បីបង្រៀនដល់បេក្ខជនត្រៀមប្រឡង ។

៣- ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំដែលចាំបាច់ទៅគណៈកម្មការប្រឡង សម្រាប់ការរៀបចំវិញ្ញាសាប្រឡង ពិនិត្យមើលសេចក្តីព្រាង និងធ្វើការជ្រើសរើសអត្ថបទចុងក្រោយ សម្រាប់វិញ្ញាសាប្រឡង ។

៤- ក្រុមប្រឹក្សាត្រូវសម្រេច ជាពិសេស ទៅលើបញ្ជីសៀវភៅ និងឯកសារ ដែលបេក្ខជនអាចប្រើប្រាស់ក្នុងពេលប្រឡង និងណែនាំលេខាធិការដ្ឋានប្រឡង អំពីវិធានការដែលត្រូវធ្វើចំពោះបេក្ខជន ដែលបានរកឃើញថា កំពុង ឬ មានបំណងលួចចម្លង ។

៥- ក្រុមប្រឹក្សាត្រូវកំណត់ពិន្ទុសម្រាប់វិញ្ញាសានីមួយៗ ត្រួតពិនិត្យពិន្ទុ ដែលផ្តល់ដោយគណៈកម្មការប្រឡង ហើយសម្រេចបឋមថា បេក្ខជនមួយណាបានប្រឡងជាប់ ឬ ធ្លាក់ ។ សមាជិកណាមួយរបស់ក្រុមប្រឹក្សា ដែលបានធ្វើជាសមាជិករបស់គណៈកម្មការប្រឡង ហើយបានឱ្យពិន្ទុបេក្ខជនប្រឡង មិនអាចចូលរួមក្នុងការសម្រេចចិត្តនេះបានទេ ។

## ប្រការ ៨ ៖ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រឡង

ក្រុមប្រឹក្សា ត្រូវកោះប្រជុំដោយប្រធានរបស់ខ្លួន។ កូរ៉ុមនៃកិច្ចប្រជុំ ដែលមានសមាជិកចំនួន ០៤(បួន) រូប អាចដំណើការកិច្ចប្រជុំបាន។ សេចក្តីសម្រេចបឋមរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចរបស់អង្គប្រជុំត្រូវយកតាមសម្លេង ៥០ ភាគរយ បូក ១ របស់សមាជិកចូលរួម ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព។

ប្រធានក្រុមប្រឹក្សាប្រឡង ត្រូវរាយការណ៍សុំសេចក្តីសម្រេចចុងក្រោយពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពីសមាសភាពបេក្ខជនដែលប្រឡងជាប់ជាស្ថាពរ។

## ប្រការ ៩ ៖ អាណត្តិរបស់ក្រុមប្រឹក្សាប្រឡង

សមាជិកក្រុមប្រឹក្សាប្រឡងដែលបានតែងតាំង នឹងកាន់មុខតំណែងមានរយៈពេល ០៣ (បី) ឆ្នាំ។ នៅពេលផុតរយៈពេលនេះ សមាជិកក្រុមប្រឹក្សាអាចត្រូវបានតែងតាំងសាជាថ្មី។

## ប្រការ ១០ ៖ គណៈកម្មការប្រឡង

១- ក្នុងការរៀបចំប្រឡង ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងគណៈកម្មការប្រឡងមួយ ឬច្រើន តាមការស្នើសុំរបស់ក្រុមប្រឹក្សាប្រឡង

២- គណៈកម្មការនីមួយៗ ត្រូវបង្កើតឡើងដោយមានការចូលរួមពីមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា និង មន្ត្រីនាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម

៣- សមាជិកច្រើនបំផុត ០៣ (បី) រូប របស់ក្រុមប្រឹក្សាប្រឡង អាចត្រូវបានតែងតាំងជាសមាជិករបស់គណៈកម្មការ។

## ប្រការ ១១ ៖ ភារកិច្ចរបស់គណៈកម្មការប្រឡង

គណៈកម្មការប្រឡង មានភារកិច្ចទទួលខុសត្រូវ ÷

១- រៀបចំវិញ្ញាសាប្រឡង ដោយអនុលោមទៅតាមការណែនាំរបស់ក្រុមប្រឹក្សា និង បញ្ជាក់ពីសារៈសំខាន់ពាក់ព័ន្ធរបស់សំណួរនីមួយៗ នៅពេលដែលចាំបាច់

២- ផ្តល់ចម្លើយនៃវិញ្ញាសាប្រឡង ជាមួយនឹងតារាងកំណត់ពិន្ទុ

៣- ប្រគល់ចម្លើយនិងពិន្ទុរបស់បេក្ខជនទៅអោយក្រុមប្រឹក្សា

៤- កិច្ចការផ្សេងៗទៀត ដែលប្រគល់ជូនដោយក្រុមប្រឹក្សា។

## ប្រការ ១២ ៖ លេខាធិការដ្ឋានប្រឡង

ក្រសួងពាណិជ្ជកម្ម នឹងផ្តល់ទីកន្លែង សម្ភាររដ្ឋបាលចាំបាច់ដែលបានមកពីការបង់ប្រាក់ឧបត្ថម្ភក្នុងការប្រឡងទៅឱ្យក្រុមប្រឹក្សា និង គណៈកម្មការប្រឡង សម្រាប់បង្កើតលេខាធិការដ្ឋានប្រឡង។

ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

## ប្រការ ១៣ ៖ ភារកិច្ចរបស់លេខាធិការដ្ឋាន

១- លេខាធិការដ្ឋានត្រូវៈ

- ជួយការងារក្រុមប្រឹក្សា និងគណៈកម្មការប្រឡង
- ផ្សព្វផ្សាយពតិមាន អំពីវគ្គបណ្តុះបណ្តាលត្រៀមប្រឡង
- ទទួលពាក្យសុំចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលត្រៀមប្រឡង និង ប្រឡង
- ត្រៀមមធ្យោបាយក្នុងការបង្រៀន និង ប្រឡង
- ចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យការប្រឡង
- បំពេញការងារផ្សេងៗតាមការណែនាំរបស់ក្រុមប្រឹក្សានិងគណៈកម្មការប្រឡង ។

២- លេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវចំពោះការបោះពុម្ពផ្សាយព័ត៌មានទាំងអស់ដែលបេក្ខជនត្រូវការ រួមមាន កាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះឈ្មោះ និងឯកសារដែលចាំបាច់នានា សម្រាប់ការដាក់ពាក្យ

៣- អនុលោមទៅតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សា លេខាធិការដ្ឋានប្រឡងនឹងសម្រេច អំពីការចុះឈ្មោះបេក្ខជន។ លេខាធិការដ្ឋានត្រូវរៀបចំធ្វើការប្រឡង ហើយចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យការប្រឡង ។

## ប្រការ ១៤ ៖ សេចក្តីជូនដំណឹងអំពីការប្រឡងជ្រើសរើស

សេចក្តីជូនដំណឹងអំពីការប្រឡងជ្រើសរើស ត្រូវផ្សព្វផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ និង ឬ បណ្តាញសារព័ត៌មាន ដែលបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះឈ្មោះ និង កាលបរិច្ឆេទនៃការប្រឡង និងឯកសារ ដែលតម្រូវ ។

## ប្រការ ១៥ ៖ ពាក្យសុំចុះឈ្មោះប្រឡង

១- ពាក្យសុំចុះឈ្មោះប្រឡង ត្រូវដាក់នៅលេខាធិការដ្ឋានប្រឡង

២- ពាក្យសុំចុះឈ្មោះត្រូវបញ្ជាក់ពី គោត្តនាម នាមខ្លួន អាសយដ្ឋាន និង សញ្ជាតិ របស់បេក្ខជន និងត្រូវ ភ្ជាប់មកជាមួយនូវ ÷

ក- ភស្តុតាងបញ្ជាក់ពីលក្ខណៈសម្បត្តិ ដូចមានចែងក្នុងប្រការ ២១

ខ- លិខិតបញ្ជាក់ថា បានបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀមដោយជោគជ័យ ដែលរៀបចំដោយ ក្រសួងពាណិជ្ជកម្ម ។

## ប្រការ ១៦ ៖ ការចុះឈ្មោះ និងសេចក្តីជូនដំណឹង

១- លេខាធិការដ្ឋានប្រឡងត្រូវជូនដំណឹងដល់បេក្ខជន អំពីការទទួលយក ឬការបដិសេធពាក្យសុំចុះឈ្មោះ របស់បេក្ខជន ។ ក្នុងករណីពាក្យស្នើសុំត្រូវបានបដិសេធ ត្រូវបញ្ជាក់ពីមូលហេតុ ។

២- កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែង នៃការប្រឡង នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

2011-01-31 Prakas Trademark Agent 28.12.11

## ប្រការ ១៧ : អនាមិកភាព

១- អនាមិកភាពនៃបេក្ខជននឹងត្រូវបានគោរព នៅពេលចម្លើយរបស់បេក្ខជនត្រូវបានដាក់ពិន្ទុ ។

២- ចម្លើយរបស់បេក្ខជនអាចត្រូវបានបោះពុម្ពផ្សាយ និងប្រើប្រាស់នៅពេលណាមួយ សម្រាប់ការស្រាវជ្រាវ សម្រាប់គោលបំណងស្ថិតិ ឬ ការបណ្តុះបណ្តាល ដោយគោរពអនាមិកភាពរបស់បេក្ខជន ។

## ប្រការ ១៨ : លទ្ធផល

១- ក្រសួងពាណិជ្ជកម្មនឹងរាយនាមនៅក្នុងបញ្ជីឈ្មោះ តាមលំដាប់ព្យញ្ជនៈរបស់បេក្ខជនដែលបានទទួលជោគជ័យក្នុងការប្រឡង ។

២- លេខាធិការដ្ឋានប្រឡងទទួលខុសត្រូវក្នុងការចងក្រង ផ្សព្វផ្សាយស្ថិតិ ស្តីពីលទ្ធផលនៃការប្រឡង ។ ក្រុមប្រឹក្សា នឹងសម្រេចអំពីព័ត៌មានដែលត្រូវផ្សព្វផ្សាយ ។

## ប្រការ ១៩ : ការរក្សាការសម្ងាត់

អនុលោមទៅតាមប្រការ១៧ សមាជិកក្រុមប្រឹក្សា សមាជិកគណៈកម្មការ និងបុគ្គលិកដែលធ្វើការនៅក្នុងលេខាធិការដ្ឋានប្រឡង ត្រូវរក្សាការសម្ងាត់ទាំងក្នុងអំឡុងពេល និងក្រោយពេលកាន់ការងារ នូវរាល់ព័ត៌មាន ទាំងអស់ និង ការពិភាក្សាណាមួយដែលធ្វើឡើងទាក់ទងនឹងបេក្ខជន ។

## ប្រការ ២០ : ការបណ្តុះបណ្តាលត្រៀមប្រឡង

១- បេក្ខជនដែលអាចចុះឈ្មោះចូលរៀនត្រៀមប្រឡង ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដោយមានបញ្ជាក់ភាពត្រឹមត្រូវ ។

២- អ្នកចូលរៀនត្រៀមប្រឡងត្រូវដាក់ពាក្យស្នើសុំ និង បង់ថ្លៃចូលរៀន តាមការកំណត់របស់ក្រុមប្រឹក្សាប្រឡង ដើម្បីសម្រួលដល់ការចំណាយចាំបាច់នានា ។

៣- មន្ត្រីរបស់ក្រសួងពាណិជ្ជកមត្រូវបានលើកលែងក្នុងការបង់ថ្លៃចូលរៀន ។

៤- វគ្គបណ្តុះបណ្តាលត្រៀមប្រឡង ត្រូវប្រើប្រាស់ពេលយ៉ាងតិចហុកសិប (៦០) ម៉ោង ។

## ប្រការ ២១ : លក្ខខណ្ឌចុះឈ្មោះប្រឡង

១- បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀម មុនកាលបរិច្ឆេទប្រឡងដែលបានរៀបចំឡើងនៅចន្លោះពេលទៀងទាត់មួយ ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២- មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានចូលបម្រើការងារយ៉ាងតិច ៥ ឆ្នាំ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង ។

៣- បេក្ខជនទាំងឡាយដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញកម្មសិទ្ធិបញ្ញា ឬខ្ពស់ជាង ដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច និងមានបទពិសោធន៍ក្នុងការងារកម្មសិទ្ធិបញ្ញា ចំនួន ៥ ឆ្នាំយ៉ាងតិច

2011 01 31 Prakas Trademark Agent ...

នៅក្នុងភ្នាក់ងារកម្មសិទ្ធិបញ្ញា ឬ ក្រុមហ៊ុនច្បាប់ ឬ ក្នុងការិយាល័យដែលទទួលបន្ទុកកម្មសិទ្ធិបញ្ញា នៃក្រុមហ៊ុនណាមួយ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង ។

៤- បេក្ខជនត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡង ។ ក្រុមប្រឹក្សាប្រឡងជាអ្នកកំណត់តម្លៃពាក្យស្នើសុំចុះឈ្មោះប្រឡង ដើម្បីមានថវិកាទ្រទ្រង់ការចំណាយចាំបាច់នានាក្នុងដំណើរការប្រឡង ។

៥- មន្ត្រីនៃក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និង លេខាធិការដ្ឋាន ដែលកំពុងកាន់មុខតំណែង មិនមានសិទ្ធិចុះឈ្មោះប្រឡងទេ ។ មន្ត្រីទាំងនោះនឹងមានសិទ្ធិចុះឈ្មោះប្រឡង បន្ទាប់ពីតំណែងរបស់ខ្លួនត្រូវបានបញ្ចប់ ។

## ប្រការ ២២ : កម្មវិធីសិក្សា និងការប្រឡង

កម្មវិធីសិក្សា និង ការប្រឡងសំដៅផ្តល់ ដល់បេក្ខជននូវចំណេះដឹងជ្រៅជ្រះពី ÷

១- សញ្ញាណជាមូលដ្ឋាននៃកម្មសិទ្ធិបញ្ញា

២- ច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជា ដែលរួមមាន : ច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និង ច្បាប់ និង បទប្បញ្ញត្តិនានា ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ របស់ព្រះរាជាណាចក្រកម្ពុជា ។

៣- ច្បាប់កម្ពុជាដទៃទៀតដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍របស់ភ្នាក់ងារតំណាងស្របច្បាប់ ។

៤- កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍ការងាររបស់ភ្នាក់ងារតំណាងស្របច្បាប់ ។

៥- ការអនុវត្តន៍ជាក់ស្តែងក្នុងការចុះបញ្ជី ការប្តឹងជំទាស់ និងដោះស្រាយវិវាទ កម្មសិទ្ធិបញ្ញា ។

## ប្រការ ២៣ : វិញ្ញាសារប្រឡង

១- ការប្រឡងមានវិញ្ញាសារសរសេរ និង ឬ ផ្ទាល់មាត់ ។

២- ក្រុមប្រឹក្សានឹងសម្រេចអំពីវិញ្ញាសា និងរយៈពេលប្រឡង ។ វិញ្ញាសាប្រឡងនឹងរៀបចំចេញពីកម្មវិធីសិក្សា ដូចក្នុងប្រការ ២២ ។

## ប្រការ ២៤ : ការដាក់ពិន្ទុ

ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំដែលចាំបាច់ដល់គណៈកម្មការប្រឡង ដើម្បីធានាឱ្យប្រាកដថា ចម្លើយរបស់បេក្ខជនត្រូវបានដាក់ពិន្ទុតាមរបៀបតែមួយ ។

## ប្រការ ២៥ : ការប្រឡងជាប់ជាស្ថាពរ

បេក្ខជន ដែលប្រឡងជាប់ជាស្ថាពរ នឹងត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ។

### ប្រការ ២៦ ៖ ករណីលើកលែងក្នុងការប្រឡង

